ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ៩ លេខ ៧៩ សប្តាហ៍ទី៤ ថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៩

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាមុន)

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសំរេច សារាចរ ប្រកាស

ក

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

១~ព្រះរាជក្រម

២២-១០-២០០៩ -ព្រះរាជក្រម នស/រកម/១០០៩/០១៨ ស្ដីពីការប្រកាសឱ្យប្រើ ច្បាប់ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្ដីពីពាណិជ្ជកម្ម សេវាកម្ម នៃកិច្ចព្រមព្រៀងក្របខណ្ឌ ស្ដីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និង សាធារណរដ្ឋប្រជាមានិតចិន ៧៧៩០

II~រាជរដ្ឋាភិបាល

១~អនុក្រឹត្យ

២០-១០-២០០៩ -អនុក្រឹត្យលេខ ១៩៤៨ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៧៨៧០

២០-១០-២០០៩ -អនុក្រឹត្យលេខ ១៩៤៩ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៧៨៧១

២០-១០-២០០៩ -អនុក្រឹត្យលេខ ១៩៥០ អនក្រ.តត ស្ដីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៧៨៧២

២០-១០-២០០៩ -អនុក្រឹត្យលេខ ១៩៥១ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៧៨៧៣

២១-១០-២០០៩ -អនុក្រឹត្យលេខ ១៩៥២ អនក្រ.តត ស្ដីពីការតែងតាំងមុខតំណែងនាយនគរបាលជាតិ ៧៨៧៤

២១-១០-២០០៩ -អនុក្រឹត្យលេខ ១៩៥៣ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៧៨៧៥

២២-១០-២០០៩ -អនុក្រឹត្យលេខ ១៩៥៤ អនក្រ.តត ស្ដីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ៧៨៧៦

២២-១០-២០០៩ -អនុក្រឹត្យលេខ ១៩៥៥ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៧៨៧៧

២២-១០-២០០៩ -អនុក្រឹត្យលេខ ១៩៥៦ អនក្រ.តត ស្ដីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលកំពង់ផែស្វយ័តក្រុងព្រះសីហនុ ៧៨៧៩

២២-១០-២០០៩ -អនុក្រឹត្យលេខ ១៩៥៧ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៧៨៨១

២២-១០-២០០៩ -អនុក្រឹត្យលេខ ១៩៥៨ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ៧៨៨២

២~សារាចរណែនាំ

២៧-១០-២០០៩ -សារាចរណែនាំលេខ ១២ សរណន ស្ដីពីការរៀបចំកែសម្រួលប្រាក់បៀវត្សរបស់ទីប្រឹក្សានាយករដ្ឋមន្ត្រី ទីប្រឹក្សាឧបនាយករដ្ឋមន្ត្រី និង ទីប្រឹក្សារាជរដ្ឋាភិបាល ព្រមទាំងសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ និង សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ៧៨៨៣

២៩-១០-២០០៩ -សារាចរណែនាំលេខ ១៣ សរណន ស្ដីពីការរៀបចំកែសម្រួលប្រាក់បៀវត្សរបស់ទីប្រឹក្សានាយករដ្ឋមន្ត្រី ទីប្រឹក្សាឧបនាយករដ្ឋមន្ត្រី និង ទីប្រឹក្សារាជរដ្ឋាភិបាល ព្រមទាំងសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ និង សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ៧៨៨៤

III-ការងារបណ្ដាក្រសួង

១-ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៤-១០-២០០៩ -ប្រកាសលេខ ២២៨ MOC/SM 2009 ស្ដីពីការគ្រប់គ្រងអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ ៧៨៨៦

២-ទីស្ដីការរដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

២១-១០-២០០៩ -សេចក្ដីណែនាំលេខ ០២៩ សណន.សក ស្ដីពីការប្ដូរអាសយដ្ឋានរបស់អ្នកបើកបរនៅលើប័ណ្ណបើកបរយានយន្ត ៧៨៨៩

៣-ទីស្ដីការរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

៣០-៩-២០០៩ -សារាចរណែនាំលេខ១៤ ដនស/សរណន អនុវត្តនីតិវិធីនៃការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ ៧៨៩០

៤-ទីស្ដីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

០៩-១០-២០០៩ -ប្រកាសលេខ ៣២០៣ ប្រក ស្ដីពីការបង្កើត មណ្ឌលអប់រំកែប្រែទី ៤ ហៅកាត់ "ម ៤" ៧៩០៥

ព្រះរាជក្រម

នស/រកម/១០០៩/០១៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីពាណិជ្ជកម្មសេវាកម្ម នៃកិច្ចព្រមព្រៀងក្របខណ្ឌ ស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និងដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់អាចពិនិត្យ និងឱ្យយោបល់តាមលក្ខខណ្ឌកំណត់ក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញបានឡើយ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE * LE MINISTÈRE DU PALAIS ROYAL

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីពាណិជ្ជកម្មសេវាកម្ម នៃកិច្ចព្រមព្រៀងក្របខណ្ឌ ស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ច ទូលំទូលាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន

មាត្រា ១.-

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីពាណិជ្ជកម្មសេវាកម្មនៃកិច្ចព្រមព្រៀងក្របខណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន ដែលបានចុះហត្ថលេខានៅទីក្រុងសេប៊ូ ប្រទេសហ្វីលីពីន នាថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៧ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

មាត្រា ៣.-

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៩

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកម.១០០៩.០៣០

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋមន្ត្រីស្តីទី

ហត្ថលេខា

គីម ស៊ីថន

លេខ ៤៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៩
អគ្គលេខាធិការរងទីស្តីការរដ្ឋាភិបាល

កិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មសេវាកម្ម នៃកិច្ចព្រមព្រៀងក្របខណ្ឌ ស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និង សាធារណរដ្ឋប្រជាមានិតចិន

រដ្ឋាភិបាលនៃប្រទេសប្រ៊ុយណេដារូស្សាឡាម (ប្រ៊ុយណេដារូស្សាឡាម) ព្រះរាជាណាចក្រកម្ពុជា (កម្ពុជា) សាធារណរដ្ឋឥណ្ឌូនេស៊ី (ឥណ្ឌូនេស៊ី) សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ (ឡាវ PDR) ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា (មីយ៉ាន់ម៉ា) សាធារណរដ្ឋហ្វីលីពីន (ហ្វីលីពីន) សាធារណរដ្ឋសិង្ហបុរី (សិង្ហបុរី) រាជាណាចក្រថៃឡង់ដ៍ (ថៃឡង់ដ៍) សាធារណរដ្ឋសង្គមនិយមវៀតណាម (វៀតណាម) ប្រទេសជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ហៅកាត់ថា "អាស៊ាន" ឬ "ប្រទេសជាសមាជិកអាស៊ាន" ឬប្រទេសនីមួយៗ "ប្រទេសសមាជិកអាស៊ានមួយ") និងសាធារណរដ្ឋប្រជាមានិតចិន ("ចិន") ។

ដោយរំលឹកឡើងវិញ នូវកិច្ចព្រមព្រៀងក្របខណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ (កិច្ចព្រមព្រៀងក្របខ័ណ្ឌ) រវាងអាស៊ាន និងចិន (ហៅកាត់ថា "បណ្តាភាគី" ឬ ភាគីនីមួយៗ ដែលសំដៅលើប្រទេសជាសមាជិកអាស៊ានមួយ ឬប្រទេសចិន គឺជា "ភាគីមួយ") ដែលបានចុះហត្ថលេខាដោយប្រមុខរដ្ឋ ឬប្រមុខរដ្ឋាភិបាលនៃប្រទេសជាសមាជិកអាស៊ាន និងប្រទេសចិន នៅភ្នំពេញថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០០២ ។

ដោយរំលឹកឡើងវិញ នូវមាត្រាទី៤ និង ទី៨ (៣) នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីការបញ្ចប់ឱ្យបានឆាប់នូវការចរចាកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មសេវាកម្ម ដើម្បីធ្វើសេរីភាវូបនីយកម្មជាបណ្តើរៗ និងលុបបំបាត់ឱ្យបានច្រើននូវការរើសអើសទាំងអស់ និង/ឬ ហាមឃាត់ចំពោះវិធានការរើសអើងថ្មីៗ ឬច្រើនថែមទៀត ចំពោះពាណិជ្ជកម្មសេវាកម្មរវាងបណ្តាភាគីពាក់ព័ន្ធ និងធ្វើការពង្រីកនូវជំរៅ និងទំហំនៃពាណិជ្ជកម្មសេវាកម្ម ដោយមានវិសាលភាពគ្របដណ្តប់ទៅលើវិស័យជាច្រើនទៀត លើសពីការសន្យារបស់ប្រទេសជាសមាជិកអាស៊ាន និងចិន ជាមួយនឹងអង្គការពាណិជ្ជកម្មពិភពលោក (WTO) ។

ដោយប្រាថ្នា ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការនៅក្នុងវិស័យសេវាកម្មរវាងភាគីទាំងអស់ ដើម្បីបង្កើននូវប្រសិទ្ធភាព និងភាពប្រកួតប្រជែង ព្រមទាំងធ្វើឱ្យការផ្គត់ផ្គង់ និងការចែកចាយសេវាបានសំបូរបែបសំរាប់អ្នកផ្គង់ផ្គង់សេវារៀងៗខ្លួន នៃបណ្តាភាគី ដើម្បីធ្វើការអនុវត្តឱ្យស្របទៅនឹងពេលកំណត់ ដែលបានព្រមព្រៀងគ្នាទៅវិញទៅមក ពីគ្រប់ភាគីទាំងអស់នៃកិច្ចព្រមព្រៀងក្របខណ្ឌ ដោយយកចិត្តទុកដាក់ដល់វិស័យ

ដែលរសើបរបស់ភាគីទាំងអស់ និងគិតគូដល់ប្រព្រឹត្តកម្មដោយឡែក និងមានភាពទន់ភ្លន់ចំពោះប្រទេសជាសមាជិកអាស៊ានថ្មី រួមមាន កម្ពុជា ឡាវ PDR មីយ៉ាន់ម៉ា និងវៀតណាម ។

ដោយទទួលស្គាល់ នូវសិទ្ធិរបស់ភាគីទាំងអស់ នៅក្នុងការត្រួតពិនិត្យ និងចេញបទប្បញ្ញត្តិថ្មីៗ ស្តីពីការផ្គត់ផ្គង់សេវាកម្ម នៅក្នុងបូរណភាពទឹកដីនៃបណ្តាភាគី ដើម្បីបំពេញទិសដៅរបស់គោលនយោបាយជាតិ ហើយដោយសារភាពខុសគ្នានៃកំរិតការអភិវឌ្ឍន៍បទប្បញ្ញត្តិសេវាកម្មនានា នៅក្នុងទឹកដីនៃបណ្តាភាគី និងតម្រូវការជាក់ស្តែងរបស់បណ្តាភាគីទាំងនោះ ក្នុងការអនុវត្តសិទ្ធិនេះ ។

បានព្រមព្រៀងដូចតទៅ :

ជំពូក I : និយមន័យ និងវិសាលភាព

មាត្រា ១

និយមន័យ

សំរាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ :

(ក) "សេវាសំរាប់ផ្គត់ផ្គង់អាជ្ញាធររដ្ឋាភិបាល" មានន័យថា ជាសេវាដែលមិនត្រូវបានផ្គត់ផ្គង់ដើម្បីផលចំណេញខាងពាណិជ្ជកម្ម និងមិនមែនសេវាដែលប្រកួតប្រជែងជាមួយអ្នកផ្គត់ផ្គង់សេវាមួយ ឬច្រើនទៀត ។

(ខ) "វត្តមានពាណិជ្ជកម្ម" មានន័យថា ជាប្រភេទធុរកិច្ច ឬការបង្កើតវិជ្ជាជីវៈណាមួយ រួមបញ្ចូលទាំង :

(i) ការបង្កើត ការទទួលបាន ឬ ការរក្សានីតិបុគ្គលដែលមានស្រាប់ ឬ

(ii) ការបង្កើត ឬការរក្សាប្រើប្រាស់សាខាក្រុមហ៊ុន ឬការិយាល័យតំណាង

នៅក្នុងដែនដីនៃភាគីមួយ សំរាប់គោលបំណងនៃការផ្គត់ផ្គង់សេវាមួយ ។

(គ) "ពន្ធផ្ទាល់"រួមបញ្ចូលនូវប្រភេទពន្ធទាំងអស់លើចំណូលសរុប លើមូលធនសរុប ឬលើសមាសធាតុចំណូល ឬមូលធន រួមមាន ពន្ធលើចំណូលពីការផ្ទេរកម្មសិទ្ធិទ្រព្យសម្បត្តិ ពន្ធលើអចលនទ្រព្យ មរតក និងអំណោយ និងពន្ធលើបរិមាណសរុបនៃប្រាក់ឈ្នួល ឬប្រាក់បៀវត្សរ៍ ដែលបើកដោយសហគ្រាសនានា ព្រមទាំងពន្ធលើកំណើនមូលធន។

(ឃ) "GATS" មានន័យថា កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម ។

(ង) "នីតិបុគ្គល" មានន័យថា នីតិបុគ្គលណាមួយ ដែលត្រូវបានបង្កើត ឬរៀបចំឡើងក្រោមច្បាប់ជាធរមាន ទោះបីជាដើម្បីរកប្រាក់ចំណេញ ឬក្នុងគោលបំណងដទៃទៀតក្តី និងទោះបីជា កម្មសិទ្ធិរបស់ឯកជន ឬ

កម្មសិទ្ធិរបស់រដ្ឋាភិបាលក្តី ដែលរួមមាន សាជីវកម្ម ក្រុមហ៊ុនទទួលភារៈគ្រប់គ្រង ក្រុមហ៊ុនសហកម្មសិទ្ធិ ក្រុមហ៊ុនចំរុះទុន សហគ្រាសឯកកម្មសិទ្ធិ ឬ សមាគម។

(ច) "នីតិបុគ្គលរបស់ភាគីមួយទៀត" មានន័យថា នីតិបុគ្គលដែល:

(i) ត្រូវបានបង្កើត ឬរៀបចំឡើងនៅក្រោមច្បាប់របស់ភាគីផ្សេងទៀត និងចូលរួមក្នុងប្រតិបត្តិការធុរកិច្ចជាដុំកំភួន នៅក្នុងដែនដីរបស់ភាគីនោះ ឬភាគីដទៃទៀត ឬ

(ii) ក្នុងករណីនៃការផ្គត់ផ្គង់សេវាតាមរយៈវត្តមានពាណិជ្ជកម្ម ការកាន់កាប់កម្មសិទ្ធិ ឬ ការគ្រប់គ្រងដោយ:

១. រូបវន្តបុគ្គលនៃភាគីនោះ ឬ

២. នីតិបុគ្គលនៃភាគីដទៃទៀត ដែលបានបង្ហាញនៅក្នុងកថាខណ្ឌរង (i)

(ឆ) នីតិបុគ្គល គឺ :

(i) ត្រូវបានកាន់កាប់កម្មសិទ្ធិ ដោយបុគ្គលទាំងឡាយនៃភាគីមួយ ប្រសិនបើលើសពី៥០ ភាគរយនៃភាគទុនរបស់ក្រុមហ៊ុន គឺត្រូវបានកាន់កាប់សិទ្ធិដោយបុគ្គលទាំងឡាយនៃភាគីនោះ

(ii) ត្រូវបានគ្រប់គ្រង ដោយបុគ្គលទាំងឡាយនៃភាគីមួយ ប្រសិនបើបុគ្គលនោះមានអំណាចតែងតាំងសមាសភាពនាយកភាគច្រើនរបស់ខ្លួន ឬមានសិទ្ធិតាមផ្លូវច្បាប់ ក្នុងការបញ្ជាឱ្យអនុវត្តសកម្មភាពរបស់ខ្លួន

(iii) ត្រូវបានចងសម្ព័ន្ធ ជាមួយបុគ្គលម្នាក់ផ្សេងទៀត នៅពេលដែលបុគ្គលនោះគ្រប់គ្រង ឬ ត្រូវបានគ្រប់គ្រងដោយបុគ្គលម្នាក់ផ្សេងទៀត ឬនៅពេលដែលបុគ្គលនោះ និងបុគ្គលម្នាក់ផ្សេងទៀតត្រូវបានគ្រប់គ្រងដូចគ្នាដោយបុគ្គលតែមួយ

(ជ) "វិធានការ" មានន័យថា វិធានការណាមួយដែលធ្វើឡើងដោយភាគីមួយ ទោះជាក្នុងទំរង់ជាច្បាប់ បទប្បញ្ញត្តិ វិធាន នីតិវិធី សេចក្តីសំរេច វិធានការរដ្ឋបាល ឬទំរង់ផ្សេងទៀត

(ឈ) "វិធានការដោយភាគីទាំងអស់" មានន័យថា ជាវិធានការនានាដែលធ្វើឡើងដោយ:

(i) រដ្ឋាភិបាល និងអាជ្ញាធរថ្នាក់កណ្តាល តំបន់ ឬ មូលដ្ឋាន និង

(ii) អង្គការក្រៅរដ្ឋាភិបាលនានា ដែលប្រើប្រាស់អំណាចប្រតិភូកម្មដោយរដ្ឋាភិបាល ឬអាជ្ញាធរថ្នាក់កណ្តាល តំបន់ ឬមូលដ្ឋាន។

(ញ) "វិធានការនានារបស់ភាគីទាំងអស់ ដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម" រួមមានវិធានការទៅលើ :

(i) ការទិញ ការទូទាត់ ឬប្រើប្រាស់សេវា

(ii) សិទ្ធិចូលរួម និងប្រើប្រាស់ ទាក់ទិននឹងការផ្គត់ផ្គង់សេវា សេវាដែលតម្រូវដោយបណ្តាភាគីសំរាប់ផ្គត់ផ្គង់ដល់សាធារណជនជាទូទៅ

(iii) វត្តមាន រួមបញ្ចូល វត្តមានពាណិជ្ជកម្ម វត្តមានបុគ្គលមកពីភាគីម្ខាង ដើម្បីផ្គត់ផ្គង់សេវានៅក្នុងដែនដីនៃភាគីម្ខាងទៀត

(ង) "អ្នកផ្គត់ផ្គង់ផ្តាច់មុខមួយចំពោះសេវាកម្មមួយ" មានន័យថា គឺជាបុគ្គលសាធារណៈ ឬឯកជន នៅក្នុងទីផ្សារពាក់ព័ន្ធនៃដែនដីរបស់ភាគីមួយ ដែលត្រូវបានអនុញ្ញាត ឬបានបង្កើតឡើងជាផ្លូវការ ឬជាឥទ្ធិពលដោយភាគីនោះ ក្នុងរូបភាពជាអ្នកផ្គត់ផ្គង់ផ្តាច់មុខនូវសេវាប្រភេទនោះ

(ច) "រូបវន្តបុគ្គលនៃភាគីមួយផ្សេងទៀត" មានន័យថា រូបវន្តបុគ្គលដែលស្នាក់អាស្រ័យនៅក្នុងដែនដីរបស់ភាគីផ្សេងទៀត ឬស្នាក់អាស្រ័យនៅកន្លែងផ្សេង និងអ្នកដែលស្ថិតនៅក្រោមច្បាប់នៃភាគីផ្សេងទៀតនោះ:

(i) ជាជនជាតិនៃភាគីដទៃទៀតនោះ ឬ

(ii) មានសិទ្ធិស្នាក់នៅអចិន្ត្រៃយ៍[១] ក្នុងដែនដីភាគីដទៃទៀតនោះ ក្នុងករណីដែលភាគីមួយផ្តល់ប្រព្រឹត្តិកម្មចំពោះអ្នកស្នាក់នៅអចិន្ត្រៃយ៍ ស្ទើរតែដូចគ្នាទាំងស្រុងនឹងប្រព្រឹត្តិកម្មដែលផ្តល់ចំពោះជនជាតិខ្លួន ពាក់ព័ន្ធនឹងវិធានការដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម ដូចបានជូនដំណឹងនៅក្នុងការទទួលយក ឬការចូលជាភាគីនៃកិច្ចព្រមព្រៀងនេះ ឱ្យតែពុំមានភាគីណាមួយត្រូវបានដាក់កាតព្វកិច្ច ឱ្យផ្តល់ចំពោះអ្នកមានសិទ្ធិស្នាក់នៅអចិន្ត្រៃយ៍នូវប្រព្រឹត្តិកម្ម ដែលមានភាពអនុគ្រោះច្រើនជាងប្រព្រឹត្តិកម្មដែលត្រូវផ្តល់ដោយភាគីដទៃទៀតនោះ ចំពោះអ្នកស្នាក់នៅអចិន្ត្រៃយ៍ទាំងនោះឡើយ។ សេចក្តីជូនដំណឹងបែបនេះ ត្រូវរួមបញ្ចូលនូវការធានា ចំពោះអ្នកស្នាក់នៅអចិន្ត្រៃយ៍ទាំងនោះ ឱ្យអនុលោមជាមួយច្បាប់ និងបទបញ្ញត្តិនានារបស់ខ្លួន ដូចគ្នានឹងការទទួលខុសត្រូវដែលភាគីដទៃទៀតប្រកាន់យកចំពោះពលរដ្ឋរបស់ខ្លួនដែរ

[១] នៅក្នុងករណីប្រ៊ុយណេដារូសាឡឹម ឥណ្ឌូនេស៊ី ឡាវ PDR ថៃឡង់ដ៍ វៀតណាម និង ប្រទេសចិន រូបវន្តបុគ្គល នៃភាគីដទៃទៀតនឹងត្រូវបានកំណត់ចំពោះរូបវន្តបុគ្គលដែលស្នាក់នៅក្នុងទឹកដីនៃភាគីទាំងនេះ ឬ កន្លែងណាមួយ និង ស្ថិតនៅក្រោមច្បាប់របស់ភាគីទាំងនោះ គឺជាអ្នកមានសញ្ជាតិនៃភាគីទាំងនោះ ។ ដូច្នេះស្ថិតក្រោមគោលការណ៍ នៃបងិ ការព្រមព្រៀងនេះមិនត្រូវបានអនុវត្តចំពោះអ្នកស្នាក់នៅអចិន្ត្រៃនៃប្រទេសឥណ្ឌូនេស៊ី ឡាវ PDR ថៃឡង់ដ៍ វៀតណាម និង ប្រទេសចិន ។ ក្នុងករណីមួយម្ភាលភាគីទាំងនេះបានអនុម័ត ច្បាប់ក្នុងប្រទេសរបស់គេស្តីពីប្រព្រឹត្តកម្មនៃអ្នកស្នាក់នៅអចិន្ត្រៃយ៍នៃភាគីដទៃ ឬ មិនមែនភាគីគួរត្រូវបានលើបញ្ហាថាតើត្រូវរួមបញ្ចូលអ្នកស្នាក់នៅអចិន្ត្រៃ ក្នុងភាពគ្របដណ្តប់ នៃរូបវន្តបុគ្គលក្រោមកិច្ចព្រមព្រៀង នេះដោយគោរពទៅតាមភាគីនោះ ។

(ខ) "បុគ្គល" មានន័យដូចគ្នានឹងរូបវន្តបុគ្គល ឬ នីតិបុគ្គល ។

(ឈ) "វិស័យ" នៃសេវាកម្មមានន័យថា :

(i) សំដៅដល់ការសន្យាតាមវិស័យមួយ ដែលមានអនុវិស័យសេវាមួយ ឬច្រើន ឬទាំងអស់ នៃសេវាកម្មមួយនោះ ដូចមានចែងនៅក្នុងតារាងនៃការសន្យារបស់ភាគីមួយ

(ii) ក្រៅពីនេះ វិស័យសេវាកម្មទាំងមូលនោះ រួមបញ្ចូលទាំងអនុវិស័យទាំងអស់របស់វាផង ដែរ

(ណ) "សេវាកម្ម" រួមបញ្ចូលនូវសេវាណាមួយនៅក្នុងវិស័យណាមួយ ដោយលើកលែងតែសេវាដែលផ្តត់ផ្គង់សំរាប់អនុវត្តន៍កិច្ចការរបស់អាជ្ញាធររដ្ឋាភិបាលចេញ

(ត) "អ្នកប្រើប្រាស់សេវា" គឺជាបុគ្គលទាំងឡាយដែលទទួល ឬ ប្រើប្រាស់សេវាមួយ

(ថ) "សេវាកម្មរបស់ភាគីម្ខាងទៀត" មានន័យថា សេវាកម្មមួយដែលត្រូវបានផ្គត់ផ្គង់ :

(i) មកពី ឬ នៅក្នុងដែនដីរបស់ភាគីដទៃទៀត ឬ នៅក្នុងករណីដឹកជញ្ជូនផ្លូវសមុទ្រ ត្រូវបានផ្គត់ផ្គង់តាមរយៈនាវាដែលបានចុះបញ្ជីក្រោមច្បាប់របស់ភាគីដទៃទៀតនោះ ឬ ដោយបុគ្គលនៃភាគីដទៃទៀតនោះ ដែលផ្គត់ផ្គង់សេវាតាមរយៈប្រតិបត្តិការនាវា និង/ ឬ ប្រើប្រាស់ទាំងស្រុង ឬ ដោយផ្នែក នូវប្រតិបត្តិការនាវានោះ ឬ

(ii) ក្នុងករណីនៃការផ្គត់ផ្គង់សេវាតាមរយៈវត្តមានពាណិជ្ជកម្ម ឬតាមរយៈវត្តមានរូបវន្តបុគ្គលដោយអ្នកផ្គត់ផ្គង់សេវានៃភាគីដទៃទៀតនោះ ៎

(ទ) "អ្នកផ្គត់ផ្គង់សេវា" មានន័យថា បុគ្គលណាម្នាក់ដែលធ្វើការផ្គត់ផ្គង់សេវា ។

(ធ) "ការផ្គត់ផ្គង់សេវា" រួមបញ្ចូលនូវ ផលិតកម្ម ការចែកចាយ ការស្វែងរកទីផ្សារ ការលក់ និងការផ្តល់សេវាមួយ ។

(ន) "ពាណិជ្ជកម្មសេវាកម្ម" ត្រូវបានកំណត់ថា ជាការផ្គត់ផ្គង់សេវា :

(i) ពីដែនដីនៃភាគីមួយទៅក្នុងដែនដីនៃភាគីណាមួយផ្សេងទៀត "ផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន" ។

(ii) នៅក្នុងដែនដីនៃភាគីមួយទៅអ្នកប្រើប្រាស់សេវានៃភាគីណាមួយផ្សេងទៀត "ការប្រើប្រាស់នៅក្រៅប្រទេស" ។

(iii) ធ្វើឡើងដោយអ្នកផ្គត់ផ្គង់សេវានៃភាគីមួយ តាមរយៈវត្តមានពាណិជ្ជកម្មនៅក្នុងដែនដីនៃភាគីណាមួយផ្សេងទៀត "វត្តមានពាណិជ្ជកម្ម" ។

(iv) ធ្វើឡើងដោយអ្នកផ្គត់ផ្គង់សេវានៃភាគីមួយ តាមរយៈវត្តមានរូបវន្តបុគ្គលរបស់ ភាគីមួយនៅក្នុងដែនដីនៃភាគីណាមួយផ្សេងទៀត "វត្តមានរូបវន្តបុគ្គល" ។

(ប) "នីតិវិធីចាំបាច់" មានន័យថា នីតិវិធីរដ្ឋបាលដែលមានការទាក់ទងនឹងការគ្រប់គ្រងតម្រូវការចាំបាច់នានា។

(ផ) "ល័ក្ខខ័ណ្ឌតម្រូវការចាំបាច់" មានន័យថា ល័ក្ខខ័ណ្ឌតម្រូវការសំខាន់ទាំងឡាយណាដែលអ្នកផ្គត់ផ្គង់សេវាតម្រូវឱ្យបំពេញ ដើម្បីទទួលបានវិញ្ញាបនប័ត្រ ឬ អាជ្ញាប័ណ្ណ ។

មាត្រា ២
វិសាលភាព

១. កិច្ចព្រមព្រៀងនេះ អនុវត្តចំពោះវិធានការនានា ដែលចាត់ឡើងដោយភាគី ដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម ។

២. កិច្ចព្រមព្រៀងនេះ មិនត្រូវអនុវត្តចំពោះ :

(ក) សេវាកម្មដែលត្រូវបានផ្គត់ផ្គង់នៅក្នុងការអនុវត្តកិច្ចការ របស់អាជ្ញាធររដ្ឋាភិបាល នៅក្នុងដែនដីរបស់ភាគីនីមួយៗ ។

(ខ) បទប្បញ្ញត្តិ ឬ ល័ក្ខខ័ណ្ឌតម្រូវគ្រប់គ្រងលើលទ្ធកម្មដែលធ្វើឡើងដោយភ្នាក់ងាររដ្ឋាភិបាលក្នុងការទិញសេវាសំរាប់គោលបំណងបម្រើឱ្យរដ្ឋាភិបាល និង និងមិនមែនក្នុងគោលបំណងលក់បន្ត ឬប្រើប្រាស់សំរាប់ផ្គត់ផ្គង់សេវា ដើម្បីផលប្រយោជន៍ពាណិជ្ជកម្ម ។

ជំពូក II : កាតព្វកិច្ច និង វិន័យ

មាត្រា ៣
តម្លាភាព

មាត្រា ៣ នៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម (GATS) ទោះជាមានការកែប្រែក៏ដោយ ក៏ត្រូវបានបញ្ចូល និងបង្កើតជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះដែរ ។

មាត្រា ៤
ការផ្សព្វផ្សាយពត៌មានសម្ងាត់

មាត្រា ៣ ស្ទួន កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម (GATS) ទោះជាមានការកែប្រែក៏ដោយ ក៏ត្រូវបានបញ្ចូល និងបង្កើតជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះដែរ ។

មាត្រា ៥

បទប្បញ្ញត្តិក្នុងស្រុក

១. នៅក្នុងវិស័យនានាដែលការសន្យាតាមវិស័យត្រូវបានធ្វើឡើងក្រោមផ្នែកទី ៣ គឺ ភាគីនីមួយៗ ត្រូវធានាថា វិធានការទាំងអស់នៃការអនុវត្តទូទៅដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម ត្រូវបានចាត់ចែងក្នុងលក្ខណៈសមស្រប សត្យានុម័ត និងមិនលំអៀង ។

២. (ក) ភាគីនីមួយៗត្រូវរក្សា ឬបង្កើតឱ្យបានឆាប់តាមដែលអាចធ្វើបាន នូវនីតិវិធី ឬវេទិការមជ្ឈត្តការ ឬរដ្ឋបាល តាមសំណើរបស់អ្នកផ្គត់ផ្គង់សេវាដែលរងការប៉ះពាល់ ដើម្បីឱ្យមានការត្រួតពិនិត្យភ្លាមៗ លើបណ្តាសេចក្តីសម្រេចរដ្ឋបាលដែលបង្អាក់ការជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម។ នៅពេលដែលនីតិវិធីទាំងនោះ មិនមានឯករាជ្យភាពពីភ្នាក់ងារសមត្ថកិច្ច ដែលចេញសេចក្តីសម្រេចរដ្ឋបាលដែលពាក់ព័ន្ធ ភាគីនោះត្រូវធានាថា នីតិវិធីទាំងនោះ នឹងត្រូវពិនិត្យឡើងវិញដោយសត្យានុម័ត និងមិនលំអៀង ។

(ខ) បទបញ្ញត្តិទាំងឡាយនៃកថាខណ្ឌរង (ក) នឹងមិនត្រូវបកស្រាយ ដើម្បីតម្រូវឱ្យភាគីណាមួយបង្កើតវេទិកា ឬនីតិវិធីទាំងនោះ ដែលមិនស្របនឹងរចនាសម្ព័ន្ធរដ្ឋធម្មនុញ្ញ ឬសារជាតិនៃប្រព័ន្ធច្បាប់របស់ខ្លួនឡើយ ។

៣. នៅពេលដែលមានតម្រូវការការអនុញ្ញាតក្នុងការផ្គត់ផ្គង់សេវាកម្មមួយ ដែលមានការសន្យាជាក់លាក់ក្រោមកិច្ចព្រមព្រៀងនេះ ដែលបានធ្វើឡើង អាជ្ញាធរមានសមត្ថកិច្ចនៃភាគីនីមួយៗត្រូវ :

(ក) តាមការស្នើសុំរបស់អ្នកដាក់ពាក្យស្នើសុំ ត្រូវកំណត់ពត៌មានបន្ថែមដែលចាំបាច់ទាំងឡាយ ដើម្បីបំពេញលើពាក្យសុំនោះ និងផ្តល់ឱកាសដល់ការធ្វើប្រាស្រ័យកែប្រែលើភាពខុសគ្នា ក្នុងអំឡុងពេលវេលាមួយសមស្រប ក្នុងករណីដែលអ្នកដាក់ពាក្យសុំនោះមិនបានបំពេញបែបបទពេញលេញ ។

(ខ) តាមសំណើរបស់អ្នកស្នើសុំ ត្រូវផ្តល់ឱ្យដោយមិនមានការពន្យាពេលដែលមិនសមស្រប អំពីពត៌មានដែលពាក់ព័ន្ធនឹងស្ថានភាពនៃពាក្យសុំ និង

(គ) ប្រសិនបើពាក្យសុំត្រូវបានបញ្ចប់ ឬ បដិសេធ ទៅតាមលទ្ធភាពជាអតិបរមាដែលអាចធ្វើទៅបាន ត្រូវជូនដំណឹងដោយគ្មានការពន្យាពេលអំពីមូលហេតុនៃការសំរេចខាងលើទៅអ្នកស្នើសុំជាលាយល័ក្ខអក្សរ ។ អ្នកស្នើសុំនឹងមានលទ្ធភាពក្នុងការដាក់ពាក្យសុំជាថ្មីឡើងវិញទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន ។

៤. ក្នុងគោលបំណងដើម្បីធានាថា វិធានការទាំងឡាយដែលទាក់ទងទៅនឹងលក្ខខ័ណ្ឌចាំបាច់ នីតិវិធី និងបទដ្ឋានបច្ចេកទេស និងលក្ខខ័ណ្ឌចាំបាច់សំរាប់ផ្តល់អាជ្ញាប័ណ្ណ មិនត្រូវបានបង្កើតឡើងជារបាំងមិនចាំបាច់ចំពោះពាណិជ្ជកម្មសេវាកម្ម បណ្តាភាគីត្រូវរួមគ្នាពិនិត្យឡើងវិញនូវលទ្ធផលនៃការចរចា អំពីវិន័យលើវិធានការទាំងនោះ ដោយគោរពទៅតាមមាត្រា VI. ៤ នៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម ក្នុងគោលបំណងបញ្ចូលលទ្ធផលទាំងនោះទៅក្នុងកិច្ចព្រមព្រៀងនេះ ។ បណ្តាភាគីបានកត់សំគាល់ថា វិន័យដែលបានដាក់ចុះទាំងនោះ គឺដើម្បីធានាដល់លក្ខខ័ណ្ឌចាំបាច់ក្នុងចំណោមនោះ ដោយ :

(ក) ត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យជាសត្យានុម័ត និងតម្លាភាព ដូចជា សមត្ថភាព និងលទ្ធភាពក្នុងការផ្គត់ផ្គង់សេវា

(ខ) មិនដាក់បន្ទុកថែមទៀតលើសពីការចាំបាច់ ដើម្បីធានាគុណភាពសេវា

(គ) នៅក្នុងករណីនីតិវិធីផ្តល់អាជ្ញាប័ណ្ណ លក្ខខ័ណ្ឌតម្រូវទាំងនោះផ្ទាល់មិនត្រូវក្លាយជាការរឹតត្បិតលើការផ្គត់ផ្គង់សេវាឡើយ ។

៥. (ក) នៅក្នុងបណ្តាវិស័យដែលភាគីមួយបានសន្យាតាមវិស័យ ក្នុងផ្នែកទី III ដែលកម្មវត្ថុនៃការរួមបញ្ចូលនូវវិន័យដែលមានចែងនៅក្នុងកថាខ័ណ្ឌទី ៤ នៃកិច្ចព្រមព្រៀងនេះ ភាគីនោះមិនត្រូវអនុវត្តចេញអាជ្ញាប័ណ្ណ លក្ខខ័ណ្ឌចាំបាច់ និងបទដ្ឋានបច្ចេកទេសនានា ដែលធ្វើឱ្យមោឃៈភាព ឬបន្ថយនូវកាតព្វកិច្ចរបស់ខ្លួន ក្រោមកិច្ចព្រមព្រៀងនេះ តាមលក្ខខ័ណ្ឌ :

(i) មិនស្របតាមលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងវាក្យខ័ណ្ឌរង៤ (ក) ,(ខ) ឬ (គ) នៃមាត្រានេះ និង

(ii) មិនអាចត្រូវបានរំពឹងទុកដោយសមហេតុផលពីសំណាក់ភាគីនោះ នៅខណៈពេលដែលការសន្យាតាមវិស័យទាំងនោះត្រូវបានធ្វើឡើង ។

(ខ) ក្នុងការកំណត់ ថាតើភាគីមួយអនុវត្តស្របតាមកាតព្វកិច្ចនៃកថាខ័ណ្ឌ ៥ (ក) នៃមាត្រានេះ ត្រូវពិចារណាលើបទដ្ឋានអន្តរជាតិនៃអង្គការអន្តរជាតិពាក់ព័ន្ធ ដែលភាគីនោះបានអនុវត្ត ។

៦. នៅក្នុងវិស័យដែលការសន្យាតាមវិស័យពាក់ព័ន្ធនឹងសេវាវិជ្ជាជីវៈត្រូវបានធ្វើឡើង ភាគីនីមួយៗ ត្រូវផ្តល់នីតិវិធីគ្រប់គ្រាន់ ដើម្បីផ្ទៀងផ្ទាត់សមត្ថភាពវិជ្ជាជីវៈនៃភាគីណាមួយផ្សេងទៀត ។

មាត្រា ៦
ការទទួលស្គាល់

១. សំរាប់គោលបំណងនៃការអនុវត្តទាំងស្រុង ឬដោយផ្នែកនូវបទដ្ឋាន ឬលក្ខណៈវិនិច្ឆ័យសំរាប់ការអនុញ្ញាត ផ្តល់អាជ្ញាប័ណ្ណ ឬចេញវិញ្ញាបនប័ត្រដល់អ្នកផ្គត់ផ្គង់សេវា ភាគីនីមួយៗអាចទទួលស្គាល់ការសិក្សាអប់រំ ឬបទពិសោធន៍ដែលទទួលបាន ការបំពេញបានតាមលក្ខខ័ណ្ឌតម្រូវ ឬអាជ្ញាប័ណ្ណ ឬវិញ្ញាបនប័ត្រ ដែលបានផ្តល់ជូនក្នុងប្រទេសរបស់ភាគីមួយទៀត ។ ការទទួលស្គាល់បែបនេះ អាចសំរេចបានតាមរយៈសុខដុមកាវូបនីយកម្ម ឬអាចផ្អែកលើកិច្ចព្រមព្រៀង ឬការរៀបចំរវាងបណ្តាភាគី ឬអង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធ ឬត្រូវបានផ្តល់ជាស្វ័យតភាព ។

២. ភាគីពីរ ឬ ច្រើន អាចចូលរួម ឬជំរុញឱ្យអង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធ ឱ្យចូលរួមធ្វើការចរចាស្តីពីការទទួលស្គាល់លើលក្ខខ័ណ្ឌចាំបាច់ នីតិវិធីចាំបាច់ ការចេញអាជ្ញាប័ណ្ណ និង/ឬ នីតិវិធីចុះបញ្ជី ដើម្បីបំពេញទៅតាមបទដ្ឋានចាំបាច់ ឬលក្ខណៈវិនិច្ឆ័យនីមួយៗ ចំពោះការផ្តល់សិទ្ធិ ការចេញអាជ្ញាប័ណ្ណ ឬវិញ្ញាបនប័ត្រ ដល់អ្នកផ្គត់ផ្គង់សេវា ។

៣. ភាគីដែលជាភាគីមួយនៃកិច្ចព្រមព្រៀង ឬការរៀបចំដែលមានចែងក្នុងកថាខណ្ឌ១ ទោះជាកំពុងមានអត្ថិភាព ឬនឹងកើតមាននាពេលអនាគតក្តី ត្រូវផ្តល់ឱកាសគ្រប់គ្រាន់ដល់ភាគីពាក់ព័ន្ធដទៃទៀត ដើម្បីអាចចូលរួមចរចាលើកិច្ចព្រមព្រៀង ឬការរៀបចំបែបនោះ ឬកិច្ចព្រមព្រៀង ឬការរៀបចំស្រដៀងគ្នា ។ នៅពេលណាដែលភាគីមួយ ផ្តល់ការទទួលស្គាល់ដោយស្វ័យតភាព ភាគីនោះត្រូវផ្តល់ឱកាសគ្រប់គ្រាន់ដើម្បីឱ្យភាគីផ្សេងទៀតបង្ហាញថា ការសិក្សាអប់រំ បទពិសោធន៍ អាជ្ញាប័ណ្ណ ឬវិញ្ញាបនប័ត្រដែលទទួលបាន ឬដែលបំពេញបានតាមលក្ខខណ្ឌតំរូវនៅក្នុងដែនដីរបស់ភាគីដទៃទៀត ក៏នឹងត្រូវបានទទួលស្គាល់ផងដែរ ។

៤. ភាគីមួយមិនត្រូវផ្តល់ការទទួលស្គាល់ក្នុងលក្ខណៈមួយ ដែលនឹងបង្កើតឱ្យមានការរើសអើងរវាងប្រទេសនានា នៅក្នុងការអនុវត្តបទដ្ឋាន ឬលក្ខណៈវិនិច្ឆ័យរបស់ខ្លួន សម្រាប់ការផ្តល់ការអនុញ្ញាតចេញអាជ្ញាប័ណ្ណ ឬវិញ្ញាបនប័ត្រដល់អ្នកផ្គត់ផ្គង់សេវា ឬការរិតត្បិតជាលក្ខណៈបិទបាំងលើពាណិជ្ជកម្មសេវាកម្ម ឡើយ ។

មាត្រា ៧
ភាពផ្តាច់មុខ និងអ្នកផ្គត់ផ្គង់សេវាផ្តាច់មុខ

១. ភាគីនីមួយៗត្រូវធានាថា អ្នកផ្គត់ផ្គង់សេវាផ្តាច់មុខណាមួយនៅក្នុងដែនដីរបស់ខ្លួន នៅក្នុងការផ្គត់ផ្គង់សេវាផ្តាច់មុខក្នុងទីផ្សារពាក់ព័ន្ធនានា នឹងមិនប្រព្រឹត្តក្នុងលក្ខណៈមួយដែលមិនស្របតាមកាតព្វកិច្ចរបស់ខ្លួន ដោយអនុលោមតាមការសន្យាតាមវិស័យឡើយ ។

២. នៅពេលដែលអ្នកផ្គត់ផ្គង់ផ្តាច់មុខរបស់ភាគីមួយ ប្រកួតប្រជែងដោយផ្ទាល់ ឬតាមរយៈក្រុមហ៊ុនសម្ព័ន្ធភាព ក្នុងការផ្គត់ផ្គង់សេវាដែលស្ថិតក្រៅវិសាលភាពនៃសិទ្ធិផ្តាច់មុខរបស់ខ្លួន និងដែលជាកម្មវត្ថុនៃការសន្យាតាមវិស័យរបស់ភាគីនោះ ភាគីនោះត្រូវធានាថា អ្នកផ្គត់ផ្គង់នេះ នឹងមិនអនុវត្តបំពាននូវតួនាទីផ្តាច់មុខរបស់ខ្លួន ក្នុងការផ្គត់ផ្គង់នៅក្នុងដែនដីរបស់ភាគី ក្នុងលក្ខណៈមួយដែលមិនសមស្របនឹងការសន្យាទាំងនោះ ។

៣. ប្រសិនបើភាគីណាមួយមានមូលហេតុដែលគួរឱ្យជឿថា អ្នកផ្គត់ផ្គង់សេវាផ្តាច់មុខនៃភាគីមួយផ្សេងទៀតកំពុងតែប្រព្រឹត្តិមិនស្របនឹងកថាខណ្ឌ១ ឬ២ នៃមាត្រានេះ ភាគីនោះអាចស្នើភាគីដែលបង្កើត រក្សាទុក ឬអនុញ្ញាតឱ្យអ្នកផ្គត់ផ្គង់សេវានោះ ផ្តល់ពត៌មានជាក់លាក់អំពីប្រតិបត្តិការពាក់ព័ន្ធរបស់ខ្លួនបាន ។

៤. បទប្បញ្ញត្តិនានានៃមាត្រានេះ ក៏ត្រូវអនុវត្តផងដែរ ចំពោះករណីដែលអ្នកផ្គត់ផ្គង់សេវាផ្តាច់មុខទាំងឡាយដែលភាគីមួយជាផ្លូវការ ឬជាឥទ្ធិពលៈ

(ក) អនុញ្ញាត ឬបង្កើតឱ្យមានអ្នកផ្គត់ផ្គង់សេវាមួយក្រុមតូច និង

(ខ) រារាំងស្ទើរតែទាំងស្រុងមិនឱ្យមានការប្រកួតប្រជែងក្នុងចំណោមអ្នកផ្គត់ផ្គង់ទាំងនោះ នៅក្នុងដែនដីរបស់ខ្លួន ។

មាត្រា ៨
ការអនុវត្តធុរកិច្ច

១. បណ្តាភាគីទទួលស្គាល់ថា ការអនុវត្តធុរកិច្ចមួយចំនួនរបស់អ្នកផ្គត់ផ្គង់សេវា ក្រៅពីការអនុវត្តដែលមានចែងក្នុងមាត្រា ៧ អាចបន្ថយបង្អាក់ការប្រកួតប្រជែង និងដោយសារហេតុផលនេះហើយ ដែលធ្វើឱ្យមានការរិតត្បិតពាណិជ្ជកម្មសេវាកម្ម ។

២. ភាគីនីមួយៗ តាមសំណើរបស់ភាគីណាមួយផ្សេងទៀត ("ភាគីស្នើសុំ") ត្រូវចូលរួមពិគ្រោះយោបល់ ក្នុងគោលបំណងដើម្បីលុបបំបាត់ការអនុវត្តនានាដែលមានចែងក្នុងកថាខណ្ឌ១ នៃមាត្រានេះ ។ ភាគីដែលត្រូវបានស្នើសុំនោះ ត្រូវពិចារណាឱ្យបានពេញលេញ និងប្រកបដោយសមានចិត្តចំពោះសំណើបែបនេះ និងត្រូវធ្វើសហប្រតិបត្តិការ តាមរយៈ ការផ្តល់ពត៌មានមិនសំងាត់ ដែលអាចរកបានជាសាធារណៈទាក់ទិននឹងបញ្ហាដែលជាកម្មវត្ថុនោះ។ ភាគីដែលត្រូវបានស្នើសុំ ក៏ត្រូវផ្តល់ផងដែរនូវពត៌មាន ដែលអាចរកបានដទៃទៀត តាមសំណើរបស់ភាគីស្នើសុំផ្អែកតាមច្បាប់ក្នុងស្រុករបស់ភាគីនោះ និងអាស្រ័យលើការព្រមព្រៀងគ្នាស្តីពីកិច្ចការពារការសំងាត់របស់ភាគីស្នើសុំ។

មាត្រា ៩

ការការពារ

១. បណ្តាភាគីកត់សំគាល់អំពីកិច្ចចរចាពហុភាគី អនុលោមតាមមាត្រា X នៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម លើបញ្ហាវិធានការការពារក្នុងសភាពអាសន្ន ផ្អែកលើគោលការណ៍មិនរើសអើង។ នៅពេលបញ្ចប់កិច្ចចរចាពហុភាគីទាំងនោះ បណ្តាភាគីត្រូវធ្វើការពិនិត្យឡើងវិញ សំដៅពិភាក្សាអំពីការធ្វើវិសោធនកម្មសមស្រប ចំពោះកិច្ចព្រមព្រៀងនេះ ដើម្បីបញ្ចូលលទ្ធផលនៃកិច្ចចរចារពហុភាគីនោះ។

២. នៅក្នុងករណីដែលការអនុវត្តកិច្ចព្រមព្រៀងនេះបណ្តាលឱ្យកើតមានផលប៉ះពាល់ធ្ងន់ធ្ងរទៅដល់វិស័យសេវាកម្មរបស់ភាគីមួយ នៅមុនការបញ្ចប់កិច្ចចរចាពហុភាគី ដែលយោងក្នុងកថាខណ្ឌ១ នៃមាត្រានេះ ភាគីដែលរងការប៉ះពាល់ អាចស្នើសុំឱ្យមានកិច្ចពិគ្រោះយោបល់ជាមួយភាគីដទៃទៀត ដើម្បីពិភាក្សាអំពីការចាត់វិធានការ លើវិស័យសេវាកម្មដែលរងការប៉ះពាល់នោះ។ វិធានការណាមួយក៏ដោយ ដែលចាត់ឡើងអនុលោមតាមកថាខណ្ឌនេះ ត្រូវតែមានការព្រមព្រៀងគ្នាទៅវិញទៅមកដោយភាគីពាក់ព័ន្ធ។ បណ្តាភាគីពាក់ព័ន្ធត្រូវយកមកពិចារណានូវកាលៈទេសៈនៃករណីជាក់ស្តែងនីមួយៗ និងផ្តល់នូវការពិចារណាប្រកបដោយសមានចិត្តចំពោះភាគីដែលស្នើសុំឱ្យចាត់វិធានការ។

មាត្រា ១០

ការទូទាត់ និងការផ្ទេរ

១. លើកលែងតែស្ថិតក្រោមកាលៈទេសៈដែលបានប្រមើទុក នៅក្នុងមាត្រា ១១ ភាគីមួយមិនត្រូវដាក់ការរិតត្បិតចំពោះការផ្ទេរ និងទូទាត់អន្តរជាតិ សម្រាប់ប្រតិបត្តិការចរន្តទាំងឡាយដែលទាក់ទិននឹងការសន្យាតាមវិស័យរបស់ខ្លួនឡើយ។

២. គ្មានអ្វីទាំងអស់នៅក្នុងកិច្ចព្រមព្រៀងនេះ ដែលនឹងត្រូវប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីណាមួយ ដែលជាសមាជិកមូលនិធិរូបិយវត្ថុអន្តរជាតិ អនុលោមតាមកិច្ចព្រមព្រៀងមូលនិធិរូបិយវត្ថុអន្តរជាតិ រួមបញ្ចូលទាំងការប្រើប្រាស់សកម្មភាពដោះដូរដោយអនុលោមតាមកិច្ចព្រមព្រៀងមូលនិធិរូបិយវត្ថុអន្តរជាតិ ឱ្យតែភាគីនោះមិនដាក់ការរិតត្បិត លើប្រតិបត្តិការមូលធនណាមួយ ផ្ទុយពីការសន្យាតាមវិស័យរបស់ខ្លួន ពាក់ព័ន្ធនឹងប្រតិបត្តិការនោះ លើកលែងតែការរិតត្បិតក្រោមមាត្រា ១១ ឬផ្អែកតាមសំណើរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ។

មាត្រា ១១
ការរិតត្បិតដើម្បីការពារជញ្ជីងទូទាត់

នៅពេលណាដែលភាគីមួយមានស្ថានភាពជញ្ជីងទូទាត់ធ្ងន់ធ្ងរ និងជួបការលំបាកខាងហិរញ្ញវត្ថុក្រៅប្រទេស ឬមានការគំរាមកំហែងពីស្ថានការណ៍បែបនោះ ភាគីនោះអាចអនុម័ត ឬរក្សាការរិតត្បិត ចំពោះពាណិជ្ជកម្មសេវាកម្មដោយអនុលោមតាមមាត្រា XII របស់កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម (GATS) ។

មាត្រា ១២
ការលើកលែងទូទៅ

យោងតាមលក្ខខណ្ឌតម្រូវដែលវិធានការបែបនេះ មិនត្រូវបានអនុវត្តក្នុងលក្ខណៈមួយដែលនឹងនាំឱ្យមានការរើសអើងដោយមិនស្មើភាព ឬគ្មានយុត្តិកម្មរវាងបណ្តាភាគីដែលមានលក្ខខណ្ឌដូចគ្នា ឬរិតត្បិតពាណិជ្ជកម្មសេវាកម្មដោយបិទបាំង គ្មានអ្វីទាំងអស់នៅក្នុងកិច្ចព្រមព្រៀងនេះដែលនឹងត្រូវបកស្រាយដើម្បីធ្វើការរារាំងដល់ការអនុម័ត ឬការអនុវត្តដោយភាគីណាមួយនូវបណ្តាវិធានការដែលៈ

ក. ចាំបាច់សម្រាប់ការពារសីលធម៌សាធារណៈ ឬដើម្បីថែរក្សាសណ្តាប់ធ្នាប់សាធារណៈ

ខ. ចាំបាច់សំរាប់ការពារជីវិត ឬ សុខភាពមនុស្ស សត្វ ឬរុក្ខជាតិ

គ. ចាំបាច់សំរាប់ធានាឱ្យមានភាពស្របតាមច្បាប់ ឬបទបញ្ជាទាំងឡាយដែលមិនផ្ទុយពីបទប្បញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះ រួមបញ្ចូលនូវអ្វីៗដែលពាក់ព័ន្ធនឹង :

(i) ការទប់ស្កាត់ការអនុវត្តបែបឆបោក និងទុច្ចរិត ឬចាត់វិធានការទល់នឹងការខកខានមិនបានបំពេញតាមកិច្ចសន្យាសេវាកម្ម ។

(ii) ការការពារជីវិតឯកជននៃបុគ្គលម្នាក់ៗទាក់ទិននឹងការស្វែងរក និងផ្សព្វផ្សាយទិន្នន័យផ្ទាល់ខ្លួន និងការការពារការសំងាត់នៃប្រវត្តិរូប និងគណនីផ្ទាល់ខ្លួន ។

(iii) សុវត្ថិភាព ។

ឃ. មិនអនុលោមតាមមាត្រា ១៩ លើកលែងតែប្រព្រឹត្តិកម្មខុសគ្នាធ្វើឡើងសំដៅ ធានាបាននូវការកំណត់ ឬប្រមូលពន្ធផ្ទាល់ប្រកបដោយសមធម៌ ឬមានប្រសិទ្ធភាព ពីសេវាកម្ម និងអ្នកផ្គត់ផ្គង់សេវារបស់ភាគីដទៃទៀត ។

ង. ដោយមានប្រព្រឹត្តិកម្មខុសគ្នា លើកលែងតែមានកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធទ្វេដង ឬ ដោយសារបទប្បញ្ញត្តិមួយចំនួនស្តីពីការចៀសវាងការយកពន្ធទ្វេដង នៅក្នុងកិច្ចព្រមព្រៀង ឬការរៀបចំអន្តរជាតិផ្សេងៗទៀត ដែលភាគីនោះត្រូវជាប់កាតព្វកិច្ច ។

មាត្រា ១៣

ការលើកលែងផ្នែកសន្តិសុខ

១. គ្មានអ្វីទាំងអស់នៅក្នុងកិច្ចព្រមព្រៀងនេះ នឹងត្រូវបកស្រាយដើម្បី :

ក. តម្រូវឱ្យភាគីណាមួយផ្តល់ពត៌មានទាំងឡាយ ដែលការទម្លាយពត៌មាននោះត្រូវបានគិតថាផ្ទុយនឹងផលប្រយោជន៍សន្តិសុខជាសារវន្តរបស់ភាគីនោះ ឬ

ខ. រារាំងភាគីណាមួយមិនឱ្យចាត់វិធានការនានាដែលគិតថាចាំបាច់សំរាប់ការពារផលប្រយោជន៍ សន្តិសុខរបស់ខ្លួន ដែលរួមមាន ប៉ុន្តែមិនកំហិតត្រឹមតែ :

(i) សកម្មភាពទាក់ទិននឹងសម្ភារៈដែលអាចបំបែក ឬរលាយបញ្ចូលគ្នាបាន ឬ សម្ភារៈនានាដែលកើតចេញពីសារធាតុទាំងនោះ

(ii) សកម្មភាពទាក់ទងនឹងការធ្វើចរាចរសព្វាវុធ គ្រាប់រំសេវ និងសម្ភារៈសង្គ្រាម និងការចរាចរនូវទំនិញ និងវត្ថុធាតុផ្សេងៗនៅក្នុងអនុវត្តដោយផ្ទាល់ ឬប្រយោល ដើម្បីផ្គត់ផ្គង់ដល់ទីតាំងយោធា ។

(iii) សកម្មភាពដែលធ្វើឡើងសំដៅការពារហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាអាយុជីវិត រួមបញ្ចូលទាំងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ទឹក និងថាមពល ពីការប៉ុនប៉ងធ្វើឱ្យខូចខាត ឬបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធទាំងនោះ

(iv) សកម្មភាពដែលធ្វើឡើងក្នុងពេលមានសង្គ្រាម ឬសភាពអាសន្នក្នុងទំនាក់ទំនងស្រុក ឬ អន្តរជាតិ ឬ

គ. រារាំងសមាជិកនានាមិនឱ្យចាត់វិធានការណាមួយ ស្របតាមកាតព្វកិច្ចរបស់ខ្លួនតាមធម្មនុញ្ញអង្គ-ការសហប្រជាជាតិ សំរាប់កិច្ចថែរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ ។

មាត្រា ១៤

ឧបត្ថម្ភធន

១. លើកលែងតែមានចែងនៅក្នុងមាត្រានេះ កិច្ចព្រមព្រៀងនេះមិនត្រូវអនុវត្តចំពោះឧបត្ថម្ភធន ឬ ជំនួយផ្សេងៗផ្តល់ដោយភាគីមួយ ឬចំពោះលក្ខខ័ណ្ឌណាមួយដែលភ្ជាប់ជាមួយនឹងការទទួល ឬការបន្តទទួលនូវឧបត្ថម្ភធន ឬជំនួយបែបនេះឡើយ ទោះបីជាឧបត្ថម្ភធន ឬជំនួយទាំងនោះត្រូវបានផ្តល់ផ្ទាល់ មុខ ឬមិនផ្ទាល់មុខចំពោះសេវាកម្មក្នុងស្រុក អ្នកប្រើប្រាស់សេវា ឬអ្នកផ្គត់ផ្គង់សេវាក៏ដោយ ។ ប្រសិនបើឧបត្ថម្ភធន ឬជំនួយទាំងនោះ ជះឥទ្ធិពលធំធេងដល់ពាណិជ្ជកម្មសេវាកម្ម ដែលបានសន្យានៅក្នុងកិច្ចព្រមព្រៀងនេះ ភាគីនានាអាចស្នើសុំពិគ្រោះយោបល់ ដើម្បីរកដំណោះស្រាយប្រកបដោយមិត្តភាពចំពោះបញ្ហានេះ ។

២. អនុលោមតាមកិច្ចព្រមព្រៀងនេះ បណ្តាភាគីត្រូវ :

ក. ផ្អែកតាមការស្នើសុំ ត្រូវផ្តល់ពត៌មានស្តីពីឧបត្ថម្ភធនទាក់ទិននឹងពាណិជ្ជកម្មសេវាកម្ម ដែលបានសន្យានៅក្នុងកិច្ចព្រមព្រៀងនេះ ជូនដល់ភាគីស្នើសុំ និង

ខ. ពិនិត្យឡើងវិញនូវប្រព្រឹត្តិកម្មនៃឧបត្ថម្ភធន នៅពេលណាវិន័យពាក់ព័ន្ធនានាត្រូវបានបង្កើតឡើងដោយអង្គការពាណិជ្ជកម្មពិភពលោក ។

មាត្រា ១៥

វិន័យអង្គការពាណិជ្ជកម្មពិភពលោក

អាស្រ័យលើកិច្ចព្រមព្រៀងអនាគតណាមួយ ដែលអាចត្រូវបានព្រមព្រៀងគ្នាអនុលោមតាមការពិនិត្យឡើងវិញនូវកិច្ចព្រមព្រៀងនេះ ដោយបណ្តាភាគីតាមមាត្រា ២៧ បណ្តាភាគីនៅពេលនេះព្រមព្រៀង និងអះអាងជាថ្មីអំពីការប្តេជ្ញារបស់ខ្លួនក្នុងការគោរពតាមបទប្បញ្ញត្តិនានា នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ដែលពាក់ព័ន្ធ និងដែលអាចអនុវត្តបានចំពោះពាណិជ្ជកម្មសេវាកម្ម ។

មាត្រា ១៦
សហប្រតិបត្តិការ

ភាគីទាំងអស់ត្រូវខិតខំពង្រឹងកិច្ចសហប្រតិបត្តិការក្នុងវិស័យសេវាកម្ម រួមទាំងវិស័យនានាដែលមិនគ្រប ដណ្តប់ដោយការរៀបចំសហប្រតិបត្តិការដែលមាន ។ បណ្តាភាគីត្រូវពិភាក្សា និងព្រមព្រៀងទៅវិញទៅមក លើវិស័យនានាសំរាប់កិច្ចសហប្រតិបត្តិការ និងបង្កើតកម្មវិធីសហប្រតិបត្តិការនៅក្នុងវិស័យទាំងនោះ ដើម្បីបង្កើន សមត្ថភាព ប្រសិទ្ធភាព និងភាពប្រកួតប្រជែងក្នុងស្រុក ។

មាត្រា ១៧
បង្កើនការចូលរួមរបស់កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម

ការបង្កើនការចូលរួមរបស់ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម នៅក្នុងពាណិជ្ជកម្មសេវាកម្ម ត្រូវបានសម្រួលតាមរយៈការសន្យាតាមវិស័យដែលបានចរចារួច ទាក់ទិននឹង :

ក. ការពង្រឹងសមត្ថភាពសេវាកម្មក្នុងស្រុករបស់ពួកគេ និងប្រសិទ្ធភាព និងភាពប្រកួតប្រជែងរបស់ សេវា ក្នុងចំណោមនោះ តាមរយៈការប្រើប្រាស់បច្ចេកវិជ្ជាលើមូលដ្ឋានពាណិជ្ជកម្ម

ខ. ការកែលំអការចូលរួមប្រើប្រាស់ខ្សែសង្វាក់ចែកចាយ និងបណ្តាញព័ត៌មាន

គ. សេរីភាវូបនីយកម្មច្រកចូលទីផ្សារនៃវិស័យ និងរបៀបនៃការផ្គត់ផ្គង់សេវាដែលមានអត្ថប្រយោ- ជន៍សម្រាប់ការនាំចេញរបស់ពួកគេ និង

ឃ. ផ្តល់ភាពទន់ភ្លន់សមស្របដល់ប្រទេស កម្ពុជា ឡាវ មីយ៉ាន់ម៉ា និង វៀតណាម ដើម្បីចរចាបើក ទូលាយវិស័យក្នុងចំនួនតិចជាង ធ្វើសេរីភាវូបនីយកម្មប្រភេទប្រតិបត្តិការក្នុងចំនួនតិចជាង និង បើកច្រកចូលទីផ្សារជាបណ្តើរៗ អាស្រ័យតាមស្ថានភាពនៃការអភិវឌ្ឍន៍របស់ប្រទេសនីមួយៗ ។

ជំពូក III ការសន្យាតាមវិស័យ

មាត្រា ១៨
ការបើកច្រកទីផ្សារ

១. ចំពោះច្រកចូលទីផ្សារតាមរយៈរបៀបនៃការផ្គត់ផ្គង់សេវាដែលមានចែងក្នុងមាត្រា១ (ន)(i)-(iv) ភាគី ត្រូវផ្តល់ដល់សេវា និងអ្នកផ្គត់ផ្គង់សេវារបស់ភាគីផ្សេងទៀត នូវប្រព្រឹត្តិកម្មមិនមានភាពអនុគ្រោះតិច

ជាងអ្វីដែលបានកំណត់នៅក្នុងលក្ខខ័ណ្ឌដែនកំណត់ និងលក្ខខ័ណ្ឌនានាដែលបានព្រមព្រៀងគ្នា និងដែលមានចែងនៅក្នុងតារាងនៃការសន្យារបស់ខ្លួនឡើយ ។

២. នៅក្នុងវិស័យទាំងឡាយដែលការសន្យាច្រកចូលទីផ្សារ ត្រូវបានធ្វើឡើង វិធានការនានាដែលភាគីមួយមិនត្រូវរក្សាទុក ឬអនុម័តយកមកប្រើប្រាស់ ទោះក្នុងមូលដ្ឋាននៃផ្នែកតូចៗនៃតំបន់ ឬក្នុង ក្របខ័ណ្ឌដែនដីទាំងមូលរបស់ខ្លួនក្តី លើកលែងតែមានការចែងផ្សេងពីនេះនៅក្នុងតារាងនៃការសន្យាតាមវិស័យរបស់ខ្លួន បើមិនដូច្នោះទេ ត្រូវបានកំណត់ដូចខាងក្រោម :

(ក) ការកំណត់លើចំនួនអ្នកផ្គត់ផ្គង់សេវា ទោះជាក្នុងទម្រង់ចំនួនកូតា ភាពផ្តាច់មុខ អ្នកផ្គត់ផ្គង់សេវាផ្តាច់មុខ ឬលក្ខខ័ណ្ឌតម្រូវនៃតម្រូវការសេដ្ឋកិច្ច

(ខ) ដាក់ការកំណត់លើតម្លៃសរុបនៃប្រតិបត្តិការសេវាកម្ម ឬទ្រព្យសម្បត្តិ ក្នុងទម្រង់បរិមាណកូតា ឬ លក្ខខ័ណ្ឌតម្រូវនៃតម្រូវការសេដ្ឋកិច្ច

(គ) ដាក់ការរឹតត្បិតលើបរិមាណសរុបនៃប្រតិបត្តិការសេវាកម្ម ឬលើបរិមាណសរុបនៃទិន្នផលសេវាកម្ម គិតជាឯកតាលេខនព្វន្តក្នុងទម្រង់កូតា ឬលក្ខខ័ណ្ឌតម្រូវនៃតម្រូវការសេដ្ឋកិច្ច ។

(ឃ) ដាក់ការកំណត់បរិមាណសរុបនៃរូបវន្តបុគ្គល ដែលអាចជួលមកធ្វើការនៅក្នុងវិស័យសេវាកម្មណាមួយ ឬការកំណត់លើរូបវន្តបុគ្គលដែលអ្នកផ្គត់ផ្គង់សេវាអាចជួលមកធ្វើការ និងរូបវន្តបុគ្គលដែលចាំបាច់ និងមានការទាក់ទិនផ្ទាល់ទៅនឹងការផ្គត់ផ្គង់សេវាណាមួយ ក្នុងទំរង់បរិមាណកូតា ឬលក្ខខ័ណ្ឌតម្រូវនៃតម្រូវការសេដ្ឋកិច្ច

(ង) វិធានការទាំងឡាយដែលរឹតត្បិត ឬតម្រូវឱ្យមានប្រភេទនីតិបុគ្គលណាមួយ ឬក្រុមហ៊ុនចម្រុះទុនដែលតាមរយៈនោះ អ្នកផ្គត់ផ្គង់សេវាធ្វើការផ្គត់ផ្គង់សេវាបាន និង

(ច) ដាក់ការកំណត់លើចំណែកមូលធនបរទេសក្នុងន័យជាការកំណត់អត្រាភាគរយអតិបរមាសម្រាប់ភាគទុនបរទេស ឬលើតម្លៃសរុបនៃវិនិយោគបរទេសនីមួយៗ ឬលើតម្លៃសរុប នៃវិនិយោគបរទេសសរុប ។

មាត្រា ១៩
ប្រព្រឹត្តិកម្មជាតិ

១. នៅក្នុងវិស័យនានាដែលមានចែងក្នុងតារាងនៃការសន្យារបស់ខ្លួន និងអាស្រ័យតាមបណ្តាលក្ខខណ្ឌ និងគុណវុឌ្ឍិកម្មដែលចែងក្នុងនោះ ភាគីនីមួយៗត្រូវផ្តល់ដល់សេវាកម្ម និងអ្នកផ្គត់ផ្គង់សេវា នៃភាគីផ្សេង

ទៀតពាក់ព័ន្ធនឹងវិធានការទាំងអស់ ដែលជះឥទ្ធិពលដល់ការផ្គត់ផ្គង់សេវានូវប្រព្រឹត្តិកម្ម មិនមានភាពអនុគ្រោះតិចជាងអ្វី ដែលបានផ្តល់ដល់សេវាកម្ម និងអ្នកផ្គត់ផ្គង់សេវាដូចគ្នារបស់ប្រទេសខ្លួនឡើយ ។

២. ភាគីមួយអាចបំពេញបាននូវលក្ខខ័ណ្ឌតម្រូវនៃកថាខ័ណ្ឌ១ នៃមាត្រានេះ តាមរយៈការផ្តល់ដល់សេវាកម្ម និងអ្នកផ្គត់ផ្គង់សេវានៃភាគីដទៃទៀត នូវប្រព្រឹត្តិកម្មដូចគ្នា ឬខុសគ្នាទៅនឹងប្រព្រឹត្តិកម្មផ្តល់ដល់សេវាកម្ម និងអ្នកផ្គត់ផ្គង់សេវា ដូចគ្នារបស់ជាតិខ្លួនផ្ទាល់ ។

៣. ប្រព្រឹត្តិកម្មដូចគ្នា ឬខុសគ្នា ត្រូវបានចាត់ទុកថា មានភាពអនុគ្រោះតិចជាង ប្រសិនបើវាបានកែប្រែលក្ខខ័ណ្ឌប្រកួតប្រជែង ដោយផ្តល់ផលប្រយោជន៍ចំពោះសេវាកម្ម និងអ្នកផ្គត់ផ្គង់សេវារបស់ភាគីមួយ ធៀបនឹងសេវាកម្ម ឬអ្នកផ្គត់ផ្គង់សេវាដូចគ្នានៃភាគីមួយផ្សេងទៀត ។

មាត្រា ២០
ការសន្យាបន្ថែម

បណ្តាភាគីអាចចរចាលើការសន្យាដែលពាក់ព័ន្ធនឹងវិធានការនានា ដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម ដែលមិនមែនជាកម្មវត្ថុការដាក់ចូលក្នុងតារាងនៃការសន្យាធ្វើឡើងនៅក្រោមមាត្រា១៨ ឬមាត្រា១៩ រួមបញ្ចូលនូវវិធានការនានាពាក់ព័ន្ធនឹងគុណវុឌ្ឍិ ស្តង់ដារ ឬអាជ្ញាប័ណ្ណ ។ ការសន្យាទាំងនេះត្រូវសរសេរនៅក្នុងតារាងនៃការសន្យារបស់ភាគី ។

មាត្រា ២១
តារាងសន្យាតាមវិស័យ

១. ភាគីទាំងអស់ត្រូវចូលរួមចរចា ដើម្បីសម្រេចនូវកញ្ចប់នៃការសន្យាតាមវិស័យ អនុលោមតាមមាត្រា ២៣ នៃកិច្ចព្រមព្រៀងនេះ ។ បណ្តាភាគីត្រូវខិតខំដើម្បីសម្រេចនូវការសន្យាឱ្យលើសពីការដែលខ្លួនបានសន្យាក្រោមកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម ។

២. ភាគីនីមួយៗ ត្រូវធ្វើតារាងសន្យាតាមវិស័យមួយ ដែលខ្លួនបានព្រមព្រៀងក្រោមមាត្រា ១៨-១៩ និង ២០ ។ ចំពោះវិស័យដែលខ្លួនបានសន្យារួចហើយ តារាងនីមួយៗត្រូវបញ្ជាក់ :

(ក) វិស័យនានាដែលបានសន្យា

(ខ) លក្ខខ័ណ្ឌ ការកំណត់ និងលក្ខខ័ណ្ឌស្តីពីការបើកច្រកទីផ្សារសេវាកម្ម

(គ) លក្ខខ័ណ្ឌ និង លក្ខខ័ណ្ឌចាំបាច់ស្តីពីប្រព្រឹត្តិកម្មជាតិ

(ឃ) ការទទួលយកដែលទាក់ទងនឹងការសន្យាបន្ថែម និង

(ង) ការកំណត់ពេលវេលាសមស្របសំរាប់អនុវត្ត នៃកិច្ចសន្យាទាំងនោះ

៣. វិធានការនានាដែលមិនស្របនឹងមាត្រា ១៨ និង ១៩ ត្រូវចុះក្នុងតារាងទាំងពីរដែលមានទាក់ទងទៅនឹងមាត្រា ១៨-១៩ ។

៤. តារាងនៃការសន្យាតាមវិស័យរបស់ភាគីមួយ ត្រូវអនុវត្តតែចំពោះភាគីទាំងនោះដែលបានបំពេញរួចរាល់នូវតារាងនៃការសន្យាតាមវិស័របស់ខ្លួនតាមរយៈការចរចា ។

៥. តារាងនៃការសន្យាតាមវិស័យរបស់បណ្តាភាគី ត្រូវភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកិច្ចព្រមព្រៀងនេះ នៅពេលការចរចាត្រូវបានសម្រេច និង ត្រូវបង្កើតជាផ្នែកមួយនៃកិច្ចព្រមព្រៀង ពីពេលនោះ ។

មាត្រា ២២
ការអនុវត្ត និងការផ្តល់ការសន្យា

១. ភាគីចិនត្រូវបង្កើតតារាងនៃការសន្យាតាមវិស័យតែមួយគត់តាមមាត្រា ២១ ហើយត្រូវអនុវត្តតារាងនៃការសន្យានេះ ចំពោះប្រទេសសមាជិកអាស៊ានទាំងអស់ ។

២. ប្រទេសសមាជិកអាស៊ាននីមួយៗ ត្រូវបង្កើតតារាងនៃការសន្យាតាមវិស័យរៀងៗខ្លួន តាមមាត្រា ២២ និងត្រូវអនុវត្តតារាងនៃការសន្យានេះចំពោះភាគីចិន និងសមាជិកអាស៊ានដទៃទៀត ។

មាត្រា ២៣
ការធ្វើសេរីភាវូបនីយកម្មជាបណ្តើរៗ

១. កញ្ចប់ដំបូងនៃការសន្យាតាមវិស័យរបស់ភាគីនីមួយៗ ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ ។

២. ក្នុងគោលបំណងដើម្បីបង្កើនការសម្រេចកញ្ចប់ទី១ នៃការសន្យាតាមវិស័យ បណ្តាភាគីត្រូវសម្រេចនូវកញ្ចប់ទី២នៃការសន្យាតាមវិស័យក្នុងរយៈពេល១ឆ្នាំ ចាប់ពីថ្ងៃដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន ។

៣. ការពិនិត្យឡើងវិញជាបន្តបន្ទាប់ទៅតាមមាត្រា ២៧ បណ្តាភាគីត្រូវចូលរួមកិច្ចចរចា ដើម្បីសម្រេចនូវកញ្ចប់ការសន្យាតាមវិស័យបន្ថែមទៀត តាមផ្នែកទី ៣ នៃកិច្ចព្រមព្រៀងនេះ ដើម្បីបន្តធ្វើសេរីភាវូបនីយកម្មបណ្តើរៗ ចំពោះពាណិជ្ជកម្មសេវាកម្មរវាងបណ្តាភាគី ។

មាត្រា ២៤
ការកែប្រែតារាងការសន្យា

១. ភាគីមួយអាចកែប្រែ ឬដកចេញនូវការសន្យាណាមួយនៅក្នុងតារាងនៃការសន្យារបស់ខ្លួននៅពេលណាមួយក៏បាន បន្ទាប់ពីរយៈពេលបីឆ្នាំបានកន្លងផុតទៅ គិតចាប់ពីកាលបរិច្ឆេទដែលការសន្យានោះបានចូលជាធរមាន ឱ្យតែ :

(ក) ភាគីនោះជូនដំណឹងដល់បណ្តាភាគី និងលេខាធិការដ្ឋានអាស៊ានអំពីចេតនារបស់ខ្លួនក្នុងការកែប្រែឬដកចេញនូវការសន្យាមិនឱ្យលើសពីបីខែមុនកាលបរិច្ឆេទ ដើម្បីចាប់ផ្តើមអនុវត្តការកែប្រែ ឬដកចេញរបស់ខ្លួន និង

(ខ) ភាគីនោះចូលរួមចរចាជាមួយភាគីរងការប៉ះពាល់ ដើម្បីព្រមព្រៀងគ្នាអំពីសំណងទូទាត់ចាំបាច់ ។

២. ដើម្បីសម្រេចបាននូវសំណងទូទាត់មួយ បណ្តាភាគីត្រូវធានាថា កម្រិតទូទៅនៃការសន្យាដែលមានផលប្រយោជន៍ទៅវិញទៅមកមិនត្រូវមានភាពអនុគ្រោះចំពោះពាណិជ្ជកម្មតិចជាងអ្វីដែលបានផ្តល់នៅក្នុងតារាងនៃការសន្យា ដែលមានមុនពេលចាប់ផ្តើមចរចាបែបនេះ ឡើយ ។

៣. សំណងទូទាត់ណាមួយដែលធ្វើឡើងស្របតាមមាត្រានេះ នឹងត្រូវផ្តល់ជូនលើមូលដ្ឋានមិនរើសអើងចំពោះភាគីទាំងអស់ ។

៤. ប្រសិនបើភាគីពាក់ព័ន្ធមិនអាចសម្រេចបាននូវកិច្ចព្រមព្រៀងស្តីពីសំណងទូទាត់ណាមួយទេនោះ បញ្ហានេះនឹងត្រូវដោះស្រាយដោយមជ្ឈត្តការ អនុលោមតាមកិច្ចព្រមព្រៀងស្តីពីយន្តការដោះស្រាយវិវាទនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ។ ភាគីដែលស្នើកែប្រែ មិនត្រូវអនុវត្តការកែប្រែ ឬដកចេញការសន្យារបស់ខ្លួនឡើយ ដោយត្រូវរង់ចាំរហូតភាគីនោះបានធ្វើសំណងទូទាត់ស្របតាមការសម្រេចរបស់មជ្ឈត្តការរួចរាល់សិន ។

៥. ប្រសិនបើភាគីកែប្រែ អនុវត្តគំរោងកែប្រែ ឬដកចេញការសន្យារបស់ខ្លួនមិនស្របតាមការសម្រេចរបស់មជ្ឈត្តការទេនោះ ភាគីនានាដែលចូលរួមក្នុងវេទិការមជ្ឈត្តការអាចកែប្រែ ឬដកចេញនូវផលប្រយោជន៍

នានាដែលសមមូលស្មើរតែទាំងស្រុង អនុលោមតាមការសម្រេចទាំងនោះ។ ទោះបីជាមានចែងក្នុងមាត្រា ២២ ក៏ដោយ ក៏ការកែប្រែ ឬដកចេញបែបនេះ អាចត្រូវបានអនុវត្តតែទៅលើភាគីកែប្រែប៉ុណ្ណោះ។

ជំពូក IV : បទប្បញ្ញត្តិផ្សេងៗ

មាត្រា ២៥

រដ្ឋាភិបាលកណ្តាល តំបន់ និងមូលដ្ឋាន

ក្នុងការបំពេញកាតព្វកិច្ច និងការសន្យារបស់ខ្លួនក្នុងកិច្ចព្រមព្រៀងនេះ ភាគីនិមួយៗត្រូវធានាថា រដ្ឋាភិបាល និងអាជ្ញាធរ តំបន់ និងមូលដ្ឋាន នៅក្នុងដែនដីរបស់ខ្លួន ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាល ប្រតិបត្តិតាមការណែនាំរបស់ខ្លួន (នៅក្នុងការអនុវត្តសិទ្ធិអំណាចដែលផ្តល់ឱ្យដោយរដ្ឋាភិបាលកណ្តាល រដ្ឋ តំបន់ ឬមូលដ្ឋាន ឬអាជ្ញាធរផ្សេងៗ) នៅក្នុងដែនដីរបស់ខ្លួន។

មាត្រា ២៦

កន្លែងទំនាក់ទំនង

១. ភាគីនិមួយៗ ត្រូវកំណត់កន្លែងទំនាក់ទំនង ដើម្បីសម្រួលការទំនាក់ទំនងរវាងបណ្តាភាគី អំពីបញ្ហាណាមួយ ដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងនេះ រួមទាំងការផ្លាស់ប្តូរពត៌មានទាក់ទងនឹងការអនុវត្ត និងប្រតិបត្តិការ នៃកិច្ចព្រមព្រៀងនេះ ។

២. តាមការស្នើសុំរបស់ភាគីណាមួយ កន្លែងទំនាក់ទំនងនៃភាគីដែលត្រូវបានស្នើសុំ ត្រូវប្រាប់ពីការិយាល័យ ឬមន្ត្រីដែលទទួលខុសត្រូវលើបញ្ហានោះ និងជួយសំរួលដល់ការទំនាក់ទំនងជាមួយភាគី ដែលស្នើសុំ។

មាត្រា ២៧

ការពិនិត្យឡើងវិញ

រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន និងរដ្ឋមន្ត្រីពាណិជ្ជកម្មចិន ឬតំណាងរបស់ពួកគេ ត្រូវជួបប្រជុំក្នុងរយៈពេលមួយឆ្នាំ គិតពីកាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ហើយបន្ទាប់ពីនោះ ត្រូវជួបគ្នារៀងរាល់ពីរឆ្នាំម្តង ឬបើមិនដូច្នោះទេ ត្រូវជួបគ្នាក្នុងចន្លោះពេលសមស្រប ដើម្បីពិនិត្យឡើងវិញនូវកិច្ចព្រមព្រៀងនេះ សំរាប់គោលបំណងនៃការពិចារណាលើការចាត់វិធានការបន្ថែមទៀត សំរាប់សេរីភាវូបនីយកម្មសេវាកម្ម និងដើម្បីបង្កើតវិន័យ និងចរចាលើកិច្ចព្រមព្រៀងនានាស្តីពីបញ្ហាដែលមានចែងនៅក្នុងមាត្រា ១៥ ឬលើបញ្ហាពាក់ព័ន្ធដទៃទៀត តាមដែលអាចព្រមព្រៀងគ្នា។

មាត្រា ២៨
បទប្បញ្ញត្តិផ្សេងៗ

១. ឧបសម្ព័ន្ធកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម គឺមាន ឧបសម្ព័ន្ធស្តីពីចលនារបស់រូបវន្តបុគ្គលដែលផ្គត់ផ្គង់សេវា ឧបសម្ព័ន្ធស្តីពីសេវាដឹកជញ្ជូនតាមផ្លូវអាកាស ឧបសម្ព័ន្ធស្តីពីសេវាហិរញ្ញវត្ថុ និងឧបសម្ព័ន្ធស្តីពីទូរគមនាគមន៍ រួមទាំងការកែប្រែនានា ត្រូវអនុវត្តចំពោះកិច្ចព្រមព្រៀងនេះ ។

២. កិច្ចព្រមព្រៀងនេះ ត្រូវរាប់បញ្ចូលនូវ (ក) ឧបសម្ព័ន្ធ និងមាតិការ នៅក្នុងនោះ នឹងត្រូវបង្កើតជាផ្នែកនៃកិច្ចព្រមព្រៀងនេះ និង (ខ) រាល់លិខិតុបករណ៍ច្បាប់អនាគតដែលបានព្រមព្រៀង ត្រូវ អនុលោមតាមកិច្ចព្រមព្រៀងនេះ ។

៣. លើកលែងតែមានការចែងផ្សេងពីនេះនៅក្នុងកិច្ចព្រមព្រៀងនេះ បើមិនដូច្នោះទេ កិច្ចព្រមព្រៀងនេះ ឬសកម្មភាពណាមួយដែលធ្វើឡើងក្រោមកិច្ចព្រមព្រៀងនេះ មិនត្រូវប៉ះពាល់ឬមោឃកម្ម ដល់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីមួយ នៅក្រោមកិច្ចព្រមព្រៀងដែលមានស្រាប់ ដែលភាគីនោះជាភាគីឡើយ ។

មាត្រា ២៩
វិសោធនកម្ម

កិច្ចព្រមព្រៀងនេះ អាចត្រូវបានធ្វើវិសោធនកម្មដោយមានការព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរពីបណ្តាភាគី ហើយវិសោធនកម្មទាំងនោះ នឹងត្រូវចូលជាធរមាននៅកាលបរិច្ឆេទ ឬបណ្តាកាលបរិច្ឆេទដែលបានព្រមព្រៀងគ្នាដោយបណ្តាភាគី ។

មាត្រា ៣០
ការដោះស្រាយវិវាទ

កិច្ចព្រមព្រៀងស្តីពីយន្តការដោះស្រាយវិវាទ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ត្រូវអនុវត្តចំពោះកិច្ចព្រមព្រៀងនេះ ។

មាត្រា ៣១
ការបដិសេធផលប្រយោជន៍

ភាគីមួយអាចបដិសេធផលប្រយោជន៍នៃកិច្ចព្រមព្រៀងនេះ ៖

ក. ចំពោះការផ្គត់ផ្គង់សេវាមួយ ប្រសិនបើរកឃើញថា សេវានោះត្រូវបានផ្គត់ផ្គង់ ចេញមកពី ឬនៅក្នុងដែនដីនៃប្រទេសមិនមែនជាភាគី

ខ. ក្នុងករណីនៃការផ្គត់ផ្គង់សេវាដឹកជញ្ជូនផ្លូវសមុទ្រ ប្រសិនបើរកឃើញថា សេវាត្រូវបានផ្គត់ផ្គង់៖

(i) ដោយនាវាដែលបានចុះបញ្ជីតាមច្បាប់របស់ប្រទេសមិនមែនភាគី និង

(ii) ដោយបុគ្គលនៃប្រទេសមិនមែនជាភាគី ដែលប្រតិបត្តិការ និង/ឬប្រើប្រាស់នាវានោះទាំងមូល ឬដោយផ្នែក ។

គ. ចំពោះអ្នកផ្គត់ផ្គង់សេវាដែលជានីតិបុគ្គល ប្រសិនបើរកឃើញថា នីតិបុគ្គលនោះមិនមែនជាអ្នកផ្គត់ផ្គង់សេវានៃភាគីម្ខាងទៀត ។

មាត្រា ៣២
ការចូលជាធរមាន

១. កិច្ចព្រមព្រៀងនេះ នឹងចូលជាធរមាននៅថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០០៧ ។

២. បណ្តាភាគីត្រូវបញ្ចប់នូវនីតិវិធីក្នុងស្រុករបស់ខ្លួន ដើម្បីចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ឱ្យបានមុនថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៧ ។

៣. នៅពេលភាគីណាមួយមិនអាចបញ្ចប់នីតិវិធីក្នុងស្រុករបស់ខ្លួនសំរាប់ការចូលជាធរមាន នៃកិច្ចព្រមព្រៀងនេះបានមុនថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០០៧ សិទ្ធិ និងកាតព្វកិច្ចនៃភាគីនោះក្រោមកិច្ចព្រមព្រៀងនេះ ត្រូវចាប់ផ្តើមអនុវត្តពីថ្ងៃដែលបានបញ្ចប់នីតិវិធីក្នុងស្រុក ។

៤. បណ្តាភាគី បន្ទាប់ពីបានសម្រេចនូវនីតិវិធីក្នុងស្រុក សំរាប់ចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅបណ្តាភាគីដទៃទៀត ។

មាត្រា ៣៣
ការតម្កល់ទុក

សំរាប់រដ្ឋជាសមាជិកអាស៊ានទាំងអស់ កិច្ចព្រមព្រៀងនេះ ត្រូវតម្កល់ទុកជាមួយអគ្គលេខាធិការអាស៊ាន ដែលជាអ្នកផ្តល់នូវសេចក្តីចម្លងតាមច្បាប់ដើមទៅប្រទេសសមាជិកអាស៊ាននីមួយៗ ។

ជាសក្ខីភាព ហត្ថលេខីខាងក្រោមដែលទទួលបានសិទ្ធប្រទានពេញលេញពីរដ្ឋាភិបាល នៃប្រទេសនីមួយៗ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មសេវាកម្ម នៃកិច្ចព្រមព្រៀងក្របខណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន ។

ធ្វើនៅទីក្រុងសេប៊ូ ប្រទេសហ្វីលីពីន ថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៧ ច្បាប់ចម្លងជាភាសាអង់គ្លេស ។

ប្រ៊ុយណេដារូសាឡាម

MOHAMED BOLKAH
រដ្ឋមន្ត្រីការបរទេស និងពាណិជ្ជកម្ម

សាធារណរដ្ឋប្រជាមានិតចិន

LI ZHAO XING
រដ្ឋមន្ត្រីការទេស

ព្រះរាជាណាចក្រកម្ពុជា

ចម ប្រសិទ្ធ
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីពាណិជ្ជកម្ម

សាធារណរដ្ឋឥណ្ឌូនេស៊ី

MARI ELKA PANGESTU
រដ្ឋមន្ត្រីពាណិជ្ជកម្ម

សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

NAM VIYAKETH
រដ្ឋមន្ត្រីឧស្សាហកម្ម និងពាណិជ្ជកម្ម

ម៉ាឡេស៊ី

DATO'SERI RAFIDAH AZIZ
រដ្ឋមន្ត្រីពាណិជ្ជកម្មអន្តរជាតិ និងឧស្សាហកម្ម

សហភាពមីយ៉ានម៉ា

U SOE THA
រដ្ឋមន្ត្រីផែនការអន្តរជាតិ និងអភិវឌ្ឍន៍សេដ្ឋកិច្ច

សាធារណរដ្ឋហ្វីលីពីន

PETER B. FAVILA
រដ្ឋមន្ត្រីពាណិជ្ជកម្ម និងឧស្សាហកម្ម

សាធារណរដ្ឋសឹង្ហបុរី

LIM HNG KIANG
រដ្ឋមន្ត្រីពាណិជ្ជកម្ម និងឧស្សាហកម្ម

រាជាណាចក្រថៃឡង់ដ៍

RIRK KRAI JIRAPAET
រដ្ឋមន្ត្រីពាណិជ្ជកម្ម

សាធារណរដ្ឋសង្គមនិយមវៀតណាម

TRUONG DINH TUYEN
រដ្ឋមន្ត្រីពាណិជ្ជកម្ម

AGREEMENT ON TRADE IN SERVICES OF THE FRAMEWORK AGREEMENT ON COMPREHENSIVE ECONOMIC CO-OPERATION BETWEEN THE ASSOCIATION OF SOUTHEAST ASIAN NATIONS AND THE PEOPLE'S REPUBLIC OF CHINA

The Governments of Brunei Darussalam ("Brunei Darussalam"), the Kingdom of Cambodia ("Cambodia"), the Republic of Indonesia ("Indonesia"), the Lao People's Democratic Republic ("Lao PDR"), Malaysia, the Union of Myanmar ("Myanmar"), the Republic of the Philippines ("Philippines"), the Republic of Singapore ("Singapore"), the Kingdom of Thailand ("Thailand") and the Socialist Republic of Viet Nam ("Viet Nam"), Member Countries of the Association of Southeast Asian Nations (collectively, "ASEAN" or "ASEAN Member Countries", or individually, "ASEAN Member Country"), and the People's Republic of China ("China"),

RECALLING the Framework Agreement on Comprehensive Economic Co-operation ("the Framework Agreement") between ASEAN and China (collectively, "the Parties", or individually referring to an ASEAN Member Country or to China as a "Party") signed by the Heads of Government/State of ASEAN Member Countries and China in Phnom Penh on the 4th day of November 2002;

RECALLING Articles 4 and 8(3) of the Framework Agreement on conclusion as expeditiously as possible of the negotiations of the agreement on trade in services so as to progressively liberalise and eliminate substantially all discrimination and/or prohibition of new or more discriminatory measures with respect to trade in services between the Parties, and to expand the depth and scope of

such trade with substantial sectoral coverage beyond those undertaken by the ASEAN Member Countries and China under the World Trade Organisation ("WTO") General Agreement on Trade in Services;

STRIVING to enhance co-operation in services between the Parties in order to improve efficiency and competitiveness, as well as to diversify the supply and distribution of services of the respective service suppliers of the Parties, for implementation in accordance with the timeframes to be mutually agreed by the Parties to the Framework Agreement taking into account the sensitive sectors of the Parties, and with special and differential treatment and flexibility for the newer ASEAN Member Countries of Cambodia, Lao PDR, Myanmar and Viet Nam;

RECOGNISING the right of the Parties to regulate, and to introduce new regulations, on the supply of services in the territories of the Parties in order to meet national policy objectives and, given asymmetries existing with respect to the degree of development of services regulation within the Parties, the particular need of the Parties to exercise this right,

HAVE AGREED AS FOLLOWS:

PART I: DEFINITIONS AND SCOPE

Article 1
Definitions

For the purposes of this Agreement:

(a) "a service supplied in the exercise of governmental authority" means any service which is supplied neither

on a commercial basis, nor in competition with one or more service suppliers;

(b) "commercial presence" means any type of business or professional establishment, including through

(i) the constitution, acquisition or maintenance of a juridical person, or

(ii) the creation or maintenance of a branch or a representative office,

within the territory of a Party for the purpose of supplying a service;

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការរបស់វិទ្យាស្ថានជាតិសុខភាពសាធារណៈ ចំនួន០៤រូប ដែលមានស្នាដៃល្អក្នុងការរៀបចំប្រមែប្រមូលធនធានមនុស្ស និងសុំជំនួយពីបរទេស ដើម្បីបង្កើតអោយមានសាលាសុខភាពសាធារណៈ បណ្តុះបណ្តាលមន្ត្រីសុខាភិបាលថ្នាក់អនុបណ្ឌិត ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :

១-ឯកឧត្តមវេជ្ជបណ្ឌិត អ៊ុំ សំអាន	នាយកវិទ្យាស្ថានជាតិសុខភាពសាធារណៈ
២-លោកបណ្ឌិត សាធុន វឌ្ឍនៈ	នាយករងវិទ្យាស្ថានជាតិសុខភាពសាធារណៈ

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ :

១-លោកឱសថការី ជួប សុខេង	ប្រធានការិយាល័យ មន្ទីរពិសោធន៍ជាតិ
២-លោក ទី សារឿន	ប្រធានការិយាល័យគណនេយ្យ

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ ១០ ឆ្នាំ ២០០៩

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ- កាលប្បវត្តិ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:១៥៥៨ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រីរាជការរបស់វិទ្យាស្ថានជាតិសុខភាពសាធារណៈ ចំនួន០៣រូប ដែលមានស្នាដៃល្អក្នុងការរៀបចំប្រមែប្រមូលធនធានមនុស្ស និង សុំជំនួយពីបរទេសដើម្បីបង្កើតអោយមានសាលាសុខភាពសាធារណៈ បណ្តុះបណ្តាលមន្ត្រីសុខាភិបាលថ្នាក់អនុបណ្ឌិត ដូចមានរាយនាមខាងក្រោម :-

១-លោកវេជ្ជបណ្ឌិត	ចាប សៀកឆាយ	អនុប្រធានការិយាល័យបច្ចេកទេស
២-លោក	ស៊ី ឡេង	អនុប្រធានការិយាល័យរដ្ឋបាល
៣-លោក	ចៅ តារាភ័ក្ត្រ	ប្រធានផ្នែកធានាគុណភាព

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ...៧ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល :</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៧ .សរណន

សារាចរណែនាំ
ស្តីពី
ការរៀបចំកែសម្រួលប្រាក់បៀវត្សរបស់ទីប្រឹក្សានាយករដ្ឋមន្ត្រី ទីប្រឹក្សាឧបនាយករដ្ឋមន្ត្រី និងទីប្រឹក្សារាជរដ្ឋាភិបាល ព្រមទាំងសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ និងសមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

កន្លងមករាជរដ្ឋាភិបាលកម្ពុជាបានធ្វើការតែងតាំងមន្ត្រីមួយចំនួន ជាទីប្រឹក្សាផ្ទាល់របស់សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ជាទីប្រឹក្សារបស់ឧបនាយករដ្ឋមន្ត្រី ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា ជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ និងសមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយផ្តល់ជូននូវ **ឋានៈស្មើ-បន្ថែមលើមុខងារបច្ចុប្បន្ន** ហើយមន្ត្រីទាំងនោះត្រូវបានរៀបចំបៀវត្សជូនតាម **ឋានៈស្មើ** ដែលមានកំរិតខ្ពស់ជាង **ឋានៈនៃមុខងារបច្ចុប្បន្ន** បន្តិច ។

ដោយសារបច្ចុប្បន្ននេះ សភាពការណ៍សេដ្ឋកិច្ចកំពុងជួបប្រទះនឹងផលវិបាកនៃវិបត្តិសេដ្ឋកិច្ចសកល ដែលតម្រូវឱ្យរាជរដ្ឋាភិបាលមានវិធានការសន្សំសំចៃថវិកាជាតិ រាជរដ្ឋាភិបាលសូមណែនាំឱ្យក្រសួង និងស្ថាប័នមានសមត្ថកិច្ច ធ្វើការរៀបចំកែសម្រួលបៀវត្សរបស់មន្ត្រីខាងលើ ដែលត្រូវបានផ្តល់ **ឋានៈស្មើ** ចាប់ពី **អនុរដ្ឋលេខាធិការ** ឡើងលើ ឱយទៅទទួលប្រាក់បៀវត្សតាមឋានៈនៃ **មុខងារបច្ចុប្បន្ន** រៀងៗខ្លួនវិញ ។

ទទួលបានសារាចរណែនាំនេះ ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី និងប្រធានស្ថាប័នមានសមត្ថកិច្ច ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧. ខែ តុលា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ*
- *ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ក្រសួង ស្ថាប័នពាក់ព័ន្ធ និងខេត្ត-រាជធានីភ្នំពេញ*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ១៣ សរណន

សារាចរណែនាំ

ស្តីពី

ការរៀបចំកែសម្រួលប្រាក់បៀវត្សរបស់ទីប្រឹក្សានាយករដ្ឋមន្ត្រី ទីប្រឹក្សាឧបនាយករដ្ឋមន្ត្រី និងទីប្រឹក្សារាជរដ្ឋាភិបាល ព្រមទាំងសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ និងសមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

កន្លងមក រាជរដ្ឋាភិបាលបានធ្វើការតែងតាំងមន្ត្រីមួយចំនួន ជាទីប្រឹក្សាផ្ទាល់របស់សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ជាទីប្រឹក្សារបស់ឧបនាយករដ្ឋមន្ត្រី ជាទីប្រឹក្សារាជរដ្ឋាភិបាល ជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ និងជាសមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយផ្តល់ជូននូវ *«ឋានៈស្មើ» បន្ថែមលើមុខងារបច្ចុប្បន្ន* ហើយមន្ត្រីទាំងនោះត្រូវបានរៀបចំបៀវត្សជូនតាម *«ឋានៈស្មើ»* ដែលមានកម្រិតខ្ពស់ជាង *ឋានៈនៃមុខងារបច្ចុប្បន្ន* ។

ដោយសារបច្ចុប្បន្ននេះ សភាពការណ៍សេដ្ឋកិច្ចកំពុងជួបប្រទះនឹងផលវិបាកនៃវិបត្តិសេដ្ឋកិច្ចសកល ដែលតម្រូវឱ្យរាជរដ្ឋាភិបាលមានវិធានការសន្សំសំចៃថវិការដ្ឋ រាជរដ្ឋាភិបាលសូមធ្វើការណែនាំឱ្យក្រសួង- ស្ថាប័នមានសមត្ថកិច្ចធ្វើការកែសម្រួលបៀវត្សរបស់មន្ត្រីខាងលើ ដូចតទៅ ÷

១- ចំពោះមន្ត្រីដែលមានឋានៈក្នុងមុខងារបច្ចុប្បន្ន *ចាប់ពីស្មើ «អនុរដ្ឋលេខាធិការ»* ឡើងទៅ *ហើយ បានទទួលការតែងតាំងក្នុង «ឋានៈស្មើ» ខ្ពស់ជាងឋានៈនៃមុខងារបច្ចុប្បន្ន* គឺត្រូវរៀបចំឱ្យទទួលប្រាក់បៀវត្ស *តាមឋានៈនៃមុខងារបច្ចុប្បន្ន* របស់ខ្លួនវិញ ។

២- ចំពោះមន្ត្រីដែលមានឋានៈក្នុងមុខងារបច្ចុប្បន្ន *ទាបជាង «អនុរដ្ឋលេខាធិការ» ហើយបានទទួលការតែងតាំងក្នុង «ឋានៈស្មើ» ខ្ពស់ជាងអនុរដ្ឋលេខាធិការ* គឺត្រូវរៀបចំឱ្យទទួលប្រាក់បៀវត្ស *ត្រឹមឋានៈ អនុរដ្ឋលេខាធិការ* ។

៣- ចំពោះមន្ត្រីដែលមានឋានៈក្នុងមុខងារបច្ចុប្បន្ន *ទាបជាង «អនុរដ្ឋលេខាធិការ» ហើយបានទទួលការតែងតាំងក្នុង «ឋានៈស្មើ» ខ្ពស់ជាងឋានៈក្នុងមុខងារបច្ចុប្បន្ន តាមលំដាប់ថ្នាក់ រហូតដល់ឋានៈស្មើអនុរដ្ឋលេខាធិការ* គឺត្រូវរៀបចំឱ្យទទួលប្រាក់បៀវត្ស *តាមឋានៈដែលទទួលបានក្នុងការតែងតាំងនៃ «ឋានៈស្មើ»* ។

ការណែនាំខាងលើនេះ ត្រូវចាប់ផ្តើមអនុវត្តពីខែ វិច្ឆិកា ឆ្នាំ ២០០៩ នេះតទៅ ។

ត្រូវចាត់ទុកជានិរាករណ៍នូវ *សារាចរណែនាំរបស់រាជរដ្ឋាភិបាល លេខ ១២ សរណន ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៩* ។

បានទទួលការណែនាំនេះហើយ ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី និងប្រធានស្ថាប័នមានសមត្ថកិច្ចត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ តុលា ឆ្នាំ ២០០៥

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ*
- *ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ក្រសួង- ស្ថាប័នពាក់ព័ន្ធ និងខេត្ត-រាជធានីភ្នំពេញ*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No. ៦២៥/ MOC / SM 2009

ប្រកាស

ស្តីពី

ការគ្រប់គ្រងអាជីវកម្មលោហធាតុត្បូងថ្មមានតំលៃជាគ្រឿងអលង្ការ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៩/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៦/១៦ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៤ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមប្រកាសលេខ ធ៩-៩៩-១០០ ប្រក ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រងអាជីវកម្មត្បូងថ្ម និងលោហធាតុមានតំលៃ របស់ធនាគារជាតិនៃកម្ពុជា
- យោងតាមលិខិតលេខ ធ៩.០៩.៥៤៨ សជណ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៩ ស្តីពីការគ្រប់គ្រងអាជីវកម្មលោហធាតុត្បូងថ្មមានតំលៃជាគ្រឿងអលង្ការ របស់ធនាគារជាតិនៃកម្ពុជា

-យោងលិខិតលេខ ១៩៩១ MOC/ SM 2009 ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៩ ស្តីពីការគ្រប់គ្រងអាជីវកម្ម លោហធាតុត្បូងថ្មមានតំលៃជាគ្រឿងអលង្ការ របស់ក្រសួងពាណិជ្ជកម្ម

-យោងតាមសេចក្តីជូនដំណឹងលេខ ធ៩.០៩.៦០១ សជណ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីការបញ្ឈប់ការផ្តល់លិខិតអនុញ្ញាតប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតំលៃជាគ្រឿងអលង្ការ របស់ធនាគារជាតិនៃកម្ពុជា

-យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

សម្រេច

ប្រការ ១: កំណត់ល័ក្ខខ័ណ្ឌនៃការគ្រប់គ្រងអាជីវកម្ម លោហធាតុត្បូងថ្មមានតំលៃជាគ្រឿងអលង្ការ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ លោហធាតុត្បូងថ្មមានតំលៃជាគ្រឿងអលង្ការ ត្រូវបានចាត់ទុកជាទំនិញមួយប្រភេទដែលធ្វើចរាចរនៅលើទីផ្សារដូចប្រភេទទំនិញដទៃទៀត ។

ប្រការ ២: រាល់អាជីវករ ពាណិជ្ជករ និងក្រុមហ៊ុនទាំងឡាយ ដែលធ្វើអាជីវកម្មលោហធាតុត្បូងថ្មមានតំលៃជាគ្រឿងអលង្ការ ត្រូវមកសុំការអនុញ្ញាតពីក្រសួងពាណិជ្ជកម្ម:

- អាជីវករ ពាណិជ្ជករ ដែលមិនជាប់ពន្ធលើប្រាក់ចំណេញ ត្រូវមកសុំលិខិតអនុញ្ញាតពីនាយកដ្ឋានជំរុញពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម
- ដោយឡែក ចំពោះអាជីវករ ពាណិជ្ជករ ដែលជាប់ពន្ធលើប្រាក់ចំណេញ ត្រូវមកសុំចុះបញ្ជីពាណិជ្ជកម្មនៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្មជាមុនសិន មុននឹងស្នើសុំលិខិតអនុញ្ញាតពីនាយកដ្ឋានជំរុញពាណិជ្ជកម្ម
- ទំរង់បែបបទនៃការសុំប្រកបអាជីវកម្ម ត្រូវមកទំនាក់ទំនងនៅមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ដែលអាជីវករ ពាណិជ្ជករនោះតាំងនៅ ។

ប្រការ ៣: អាជីវករ ពាណិជ្ជករ ដែលបានទទួលការអនុញ្ញាតឱ្យប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតំលៃជាគ្រឿងអលង្ការ ត្រូវប្រកបមុខរបររបស់ខ្លួននៅក្នុងទីតាំងដែលអាជ្ញាធរមានសមត្ថកិច្ចបានកំណត់ ត្រូវបិទស្លាកថ្លៃលើគ្រឿងអលង្ការនីមួយៗឱ្យបានច្បាស់លាស់ និងត្រូវមានវិក្កយបត្រជូនអតិថិជន រាល់ការលក់។ វិក្កយបត្រត្រូវមានបញ្ជាក់អំពី នាមករណ៍ អាសយដ្ឋានអាជីវកម្ម លេខទូរស័ព្ទ និងកំណត់សំគាល់ផ្សេងៗទៀត ។

ប្រការ ៤: អាជីវករ ពាណិជ្ជករ ដែលបានធ្វើអាជីវកម្មលោហធាតុត្បូងថ្មមានតំលៃជាគ្រឿងអលង្ការ ត្រូវធ្វើការបញ្ជាក់ឱ្យបានច្បាស់លាស់នូវគុណភាពរបស់ផលិតផលខ្លួន នៅលើវិក្កយបត្រដែលបានផ្តល់ជូនអតិថិជន។ អាជីវករ ពាណិជ្ជករទាំងឡាយណាដែលបានក្លែងបន្លំ ភូតភរ រំលោភសេចក្តីទុកចិត្ត ឬឆបោកអតិថិជនត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ។

ប្រការ ៥: លិខិតអនុញ្ញាតឱ្យប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតំលៃជាគ្រឿងអលង្ការ ដែលចេញដោយក្រសួងពាណិជ្ជកម្ម មានសុពលភាពសំរាប់រយៈពេល ១២ខែ គិតចាប់ពីថ្ងៃផ្តល់ជូន ។ អាជីវករ ពាណិជ្ជករ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន

លេខ: ០២៩ សាធ.ដក ...សក

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ 2009

សេចក្តីណែនាំ
ស្តីពី
ការប្តូរអាសយដ្ឋានរបស់អ្នកបើកបរនៅលើប័ណ្ណបើកបរយានយន្ត

កន្លងមក ក្រសួងសាធារណការ និងដឹកជញ្ជូន សង្កេតឃើញថា អ្នកបើកបរមួយចំនួនបានធ្វើការប្តូរអាសយដ្ឋាន ទៅរស់នៅកន្លែងផ្សេង ហើយដើម្បីងាយស្រួលដល់អាជ្ញាធរមានសមត្ថកិច្ចក្នុងការស្រាវជ្រាវរកអាសយដ្ឋានអ្នកបើកបរយានយន្ត ក្រសួងសាធារណការ និងដឹកជញ្ជូន សូមធ្វើការណែនាំ អគ្គនាយកដ្ឋានដឹកជញ្ជូន និងគ្រប់មន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានី ខេត្ត ដូចខាងក្រោម :

ក-អគ្គនាយកដ្ឋានដឹកជញ្ជូន

១-ចេញប័ណ្ណបើកបរយានយន្តដល់អ្នកបើកបរ ដែលបានប្តូរអាសយដ្ឋានពីរាជធានីទៅរស់នៅបណ្តាខេត្ត ឬពីបណ្តា ខេត្ត ទៅរស់នៅរាជធានី ឬពីខេត្តមួយទៅរស់នៅខេត្តមួយផ្សេងទៀត ។

២-រាល់ការផ្លាស់ប្តូរអាសយដ្ឋានខាងលើនេះ ត្រូវមានការបញ្ជាក់ពីមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ដែលបានចេញប័ណ្ណបើកបរយានយន្តនៅអាសយដ្ឋានចាស់ ។

៣-រាល់ការចេញប័ណ្ណបើកបរយានយន្ត ត្រូវរក្សាអត្តសញ្ញាណអ្នកបើកបរ និងលេខប័ណ្ណបើកបរឱ្យនៅដដែល ប៉ុន្តែគ្រាន់ តែធ្វើការប្តូរអាសយដ្ឋានប៉ុណ្ណោះ ។

៤-ត្រូវធ្វើការកត់ត្រាអាសយដ្ឋានក្នុងសៀវភៅបញ្ជីធំដោយឡែក សម្រាប់ការប្តូរអាសយដ្ឋានឆ្លងរាជធានី ខេត្ត ឱ្យបានច្បាស់លាស់ ។

៥-ចំពោះអ្នកបើកបរត្រូវមានលិខិតបញ្ជាក់កាយសម្បទាថ្មី ហើយប័ណ្ណបើកបរត្រូវកំណត់សុពលភាពប្រើប្រាស់ជាថ្មីដែរ ។

ខ-មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត

១-ត្រូវប្តូរអាសយដ្ឋានថ្មីរបស់អ្នកបើកបរយានយន្ត ដែលមានអាសយដ្ឋានស្ថិតក្នុងរាជធានី ខេត្ត របស់ខ្លួនប៉ុណ្ណោះ ។ ចំពោះការចេញប័ណ្ណនេះត្រូវធ្វើសម្រាប់តែប័ណ្ណបើកបរ ដែលបានចេញដោយមន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានី ខេត្ត របស់ខ្លួន ។

២-ត្រូវធ្វើការកត់ត្រាក្នុងតល់បញ្ជីរបស់អ្នកបើកបរយានយន្ត ដែលបានប្តូរទៅរស់នៅអាសយដ្ឋានថ្មី ។

៣-ចំពោះអ្នកបើកបរត្រូវមានលិខិតបញ្ជាក់កាយសម្បទាថ្មី ហើយប័ណ្ណបើកបរត្រូវកំណត់សុពលភាពប្រើប្រាស់ជាថ្មីដែរ ។

ទទួលបានការណែនាំនេះ សូមឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានដឹកជញ្ជូន និងលោកប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានី ខេត្ត ត្រូវចាត់តាំងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ត្រាំ អ៊ីវតឹក

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យលោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី ប្រចាំការ
-ខុទ្ទកាល័យឯកឧត្តម យឹម ឆៃលី ឧបនាយករដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-សាលារាជធានី ខេត្ត
-អគ្គនាយកដ្ឋានដឹកជញ្ជូន
-នាយកដ្ឋានដឹកជញ្ជូនផ្លូវគោក
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ដែលបន្តអាជីវកម្មរបស់ខ្លួនត្រូវដាក់ពាក្យសុំជាថ្មី ក្នុងរយៈពេល៣០ថ្ងៃយ៉ាងយឺតបំផុត មុនថ្ងៃផុតកំណត់សុពលភាពនីមួយៗ។

<u>**ប្រការ ៦:**</u> លិខិតអនុញ្ញាតឱ្យប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតំលៃជាគ្រឿងអលង្ការនេះ ត្រូវដកហូតវិញមុនសុពលភាព ក្នុងករណីដែលអាជីវករ ពាណិជ្ជករ មិនគោរពតាមកិច្ចសន្យាសុំប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតំលៃជាគ្រឿងអលង្ការ និងមិនគោរពតាមខ្លឹមសារក្នុងប្រការ៣ និងប្រកា៤ នៃប្រកាសនេះ។

<u>**ប្រការ ៧:**</u> ក្នុងករណីផ្អាក ឬបញ្ឈប់សកម្មភាព ឬប្តូរទីតាំងអាជីវកម្ម អាជីវករ ពាណិជ្ជករ ត្រូវធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរ មកក្រសួងពាណិជ្ជកម្មឱ្យបានមុន ៣០ថ្ងៃ។

<u>**ប្រការ ៨:**</u> អាជីវករ ពាណិជ្ជករ ដែលធ្វើអាជីវកម្មលោហធាតុត្បូងថ្មមានតំលៃជាគ្រឿងអលង្ការ មិនគោរពតាមប្រកាសនេះ នឹងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

<u>**ប្រការ ៩:**</u> ចំពោះនីតិវិធី និងទំរង់បែបបទនៃការស្នើសុំធ្វើអាជីវកម្មលោហធាតុត្បូងថ្មមានតំលៃជាគ្រឿងអលង្ការ ត្រូវបានកំណត់តាមសេចក្តីណែនាំដោយឡែករបស់ក្រសួងពាណិជ្ជកម្ម។

<u>**ប្រការ ១០:**</u> ប្រកាស និងបទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

<u>**ប្រការ ១១:**</u> នាយិកាខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានពាក់ព័ន្ធ និងប្រធានមន្ទីរពាណិជ្ជកម្ម រាជធានី-ខេត្ត ត្រូវអនុវត្តតាមប្រកាសនេះ។

<u>**ប្រការ ១២:**</u> ប្រកាសនេះមានប្រសិទ្ធភាព និងអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៩

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

<u>**ចម្លងជូន**</u>

-ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
-ខុទ្ទកាល័យ លោកជំទាវឧបនាយករដ្ឋមន្ត្រីប្រចាំការ **ម៉ែន សំអន**
-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងទេសចរណ៍
-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
-ក្រសួងព័ត៌មាន
-ធនាគារជាតិនៃកម្ពុជា
"<u>ដើម្បីជ្រាបជាព័ត៌មាន</u>"
-សាលារាជធានី-ខេត្ត "<u>ដើម្បីសហការអនុវត្ត</u>"
-ដូចប្រការ ១១ "<u>ដើម្បីអនុវត្ត</u>"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨២៧ ៣៥៨ / ២១៨ ៩៨៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៨៨ / ៩៩១-៧០៨

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ : ១៤៥ ដនស/សរណន

ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៥

សារាចរណែនាំ

អនុវត្តនីតិវិធីនៃការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ

អនុលោមតាមអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ ក្រសួងរៀបចំដែនដី នគរូនីយកម្ម និង សំណង់ សូមធ្វើការណែនាំដូចតទៅ :

ដំណាក់កាលទី១ : **អំពីការដាក់ពាក្យស្នើសុំចុះបញ្ជីដី** :

អ្នកកាន់កាប់ដីដែលមានបំណងស្នើសុំចុះបញ្ជីក្បាលដីរបស់ខ្លួន (ទោះមានទំហំប៉ុន្មានក្តី) ត្រូវបំពេញពាក្យសុំតាមគំរូដែលបានរៀបចំ ដាក់ជូនរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ក្រុង តាមរយៈមេឃុំ ចៅសង្កាត់ នៃឃុំ សង្កាត់ដែលក្បាលដី នោះស្ថិតនៅ ។

ពាក្យស្នើសុំត្រូវធ្វើជាពីរច្បាប់ និងអាចមានឯកសារណាបផ្សេងៗភ្ជាប់មកជាមួយ ដូចជា ឯកសារ និង ភស្តុតាង ទាក់ទងនឹងក្បាលដី ឬសិទ្ធិលើក្បាលដីដែលស្នើសុំចុះបញ្ជី ។

មេឃុំ ចៅសង្កាត់ ត្រូវពិនិត្យមើលពាក្យស្នើសុំ ណែនាំឱ្យសាមីអ្នកកាន់កាប់ដីបំពេញបានគ្រប់គ្រាន់ តាមខ្លឹមសារដែលបានរៀបចំ ថាតើសេចក្តីដែលសាមីអ្នកស្នើសុំបានបំពេញនោះសមស្របតាមហេតុការណ៍ដែលបានកើតឡើងជាក់ស្តែង ដែរ ឬទេ ?

ចំណុចដែលត្រូវយកចិត្តទុកដាក់ ជាសំខាន់នោះ គឺលក្ខណៈនៃការចូលកាន់កាប់ដីមានប្រើអំពើហិង្សា ឬគ្មាន ? កាលបរិច្ឆេទនៃការចូលកាន់កាប់ដី ពិតប្រាកដដែរ ឬទេ ? ទីតាំងក្បាលដី មានប៉ះពាល់ដល់ទ្រព្យសាធារណៈរបស់រដ្ឋ ដែរ ឬទេ ? ក្បាលដីដែលកំពុងស្នើសុំចុះបញ្ជី មានទំនាស់ ដែរ ឬទេ ?

បន្ទាប់ពីពិនិត្យឃើញថា ពាក្យស្នើសុំមានលក្ខណៈគ្រប់គ្រាន់ហើយ មេឃុំឬចៅសង្កាត់នោះ ត្រូវចារលើពាក្យស្នើសុំ រួចធ្វើបែបបទបញ្ជូនពាក្យស្នើសុំទាំងនោះមករដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ក្រុង ។

រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ក្រុង ត្រូវត្រួតពិនិត្យពាក្យស្នើសុំចុះបញ្ជី ដោយផ្អែកលើគោលការណ៍ជំនាញ និងច្បាប់ :

- ក្នុងករណីពិនិត្យឃើញថា ពាក្យស្នើសុំមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ក្រុង ត្រូវកត់ត្រាពាក្យស្នើសុំទាំងនោះចូលក្នុងសៀវភៅទទួលពាក្យចុះលេខ រួចចារលើពាក្យនោះ កំណត់កាលបរិច្ឆេទ និងទីកន្លែងដែលត្រូវចុះអនុវត្តកំណត់ព្រំដី វាស់វែង និងវិនិច្ឆ័យ ហើយប្រគល់ពាក្យមួយច្បាប់ជូនអ្នកដាក់ពាក្យវិញ។ ប្រសិនបើមានក្បាលដីច្រើនមានទីតាំងស្ថិតនៅជាប់ៗគ្នា ឬជិតៗគ្នា ក្នុងឃុំ សង្កាត់ជាមួយគ្នា ហើយទទួលបានការយល់ព្រមឱ្យអនុវត្តនីតិវិធីចុះបញ្ជី និងកំណត់កាលបរិច្ឆេទចុះអនុវត្តការងារវាលថ្ងៃជាមួយគ្នា ពាក្យស្នើសុំចុះបញ្ជីក្បាលដីទាំងនោះ អាចត្រូវបានប្រមូលផ្តុំទៅតាមលទ្ធភាពដែលក្រុមការងារវាល អាចអនុវត្តបានក្នុងមួយថ្ងៃ ដើម្បីបង្កើតបញ្ជីឈ្មោះអ្នកស្នើសុំចុះបញ្ជីដី និងធ្វើសេចក្តីជូនដំណឹងតែមួយ ដាក់ជូនអភិបាលស្រុកខណ្ឌក្រុង ចុះហត្ថលេខាក្នុងរយៈពេលមិនលើសពីពាថ្ងៃ បន្ទាប់ពីរដ្ឋបាលសុរិយោដីស្រុកខណ្ឌក្រុងលើកសំណើដើម្បីកំណត់ជាផ្លូវការនូវកាលបរិច្ឆេទ និងទីកន្លែងដែលត្រូវអនុវត្ត ។ សេចក្តីជូនដំណឹងនេះ ត្រូវប្រគល់ជូនអ្នកដាក់ពាក្យស្នើសុំ និងបិទផ្សាយឱ្យបានយ៉ាងតិច ១៤ (ដប់បួន) ថ្ងៃ មុនកាលបរិច្ឆេទនៃការចុះកំណត់ព្រំដី នៅសាលាស្រុក ខណ្ឌ ក្រុង សាលាឃុំ សង្កាត់ និងនៅ កន្លែងដែលងាយមើលឃើញក្នុងភូមិដែលក្បាលដី ស្នើសុំចុះបញ្ជីនោះស្ថិតនៅ ។
- ក្នុងករណីពិនិត្យឃើញថា កាលបរិច្ឆេទនៃការចូលកាន់កាប់ដីរដ្ឋ កើតឡើងក្រោយថ្ងៃ ៣០ សីហា ២០០១ រដ្ឋបាលសុរិយោដីស្រុកខណ្ឌក្រុង ត្រូវចារលើពាក្យស្នើសុំឱ្យបានច្បាស់អំពី ភាពខុសច្បាប់នៃការចូលកាន់កាប់ដី ហើយប្រគល់ពាក្យនោះទៅសាមីអ្នកស្នើសុំវិញ ។

- ក្នុងករណីពិនិត្យឃើញថា ការកាន់កាប់ដីមានលក្ខណៈមិនសមស្រប ពិសេសការចូលកាន់កាប់ដោយទុច្ចរិត (ប្រើហិង្សា ឬលួងលោមបោកបញ្ឆោត) ដោយលួចលាក់ ឬមិនចេញមុខ រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ក្រុង ត្រូវចារលើពាក្យ ដោយបញ្ជាក់ឱ្យបានច្បាស់អំពីមូលហេតុ និងភស្តុតាងដែលនាំឱ្យការអនុវត្តនីតិវិធីចុះបញ្ជីដី មិនអាចប្រព្រឹត្តទៅបាន រួចប្រគល់ ពាក្យនោះ ទៅសាមីអ្នកស្នើសុំវិញ ។
- ក្នុងករណីពិនិត្យឃើញថា ដីដែលស្នើសុំចុះបញ្ជី ជាដីសាធារណៈរបស់រដ្ឋ រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ក្រុង ត្រូវចារលើពាក្យដោយបញ្ជាក់ឱ្យបានច្បាស់អំពីមូលហេតុនិងភស្តុតាងដែលនាំឱ្យការអនុវត្តនីតិវិធីចុះបញ្ជីដីមិនអាចប្រព្រឹត្តទៅបាន រួចប្រគល់ពាក្យនោះទៅឱ្យសាមីអ្នកស្នើសុំវិញ លើកលែងតែអ្នកស្នើសុំនោះជានីតិបុគ្គលសាធារណៈ ។
- ក្នុងករណីពិនិត្យឃើញថា មានវិវាទពាក់ព័ន្ធនឹងក្បាលដីដែលស្នើសុំចុះបញ្ជីនោះ រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ក្រុង ត្រូវបញ្ជូនសំណុំរឿងវិវាទនោះទៅគណៈកម្មការសុរិយោដីដោះស្រាយតាមនីតិវិធី ។
- គ្រប់ករណីដែលរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ក្រុងបដិសេធមិនព្រមអនុវត្តនីតិវិធីនៃការចុះបញ្ជីដីតាមការស្នើសុំ សាមីអ្នកស្នើសុំ ឬតំណាងស្របច្បាប់របស់ជននេះ មានសិទ្ធិប្តឹងត៍វ៉ាទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត ឬក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីដី ត្រូវបង់សោហ៊ុយសេវាសុរិយោដីទៅតាមការកំណត់របស់រដ្ឋ ។

ដំណាក់កាលទី ២ : **អំពីកិច្ចប្រតិបត្តិការបច្ចេកទេស** :

១. **អំពីការងារវាល** :

យោងតាមការណែនាំរបស់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ និងការណែនាំជាក់ស្តែងរបស់ថ្នាក់ដឹកនាំរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ក្រុង តាមលក្ខណៈភូមិសាស្ត្រដោយឡែកៗ ការងារវាលត្រូវបានអនុវត្តដោយមន្ត្រីជំនាញ ដោយមានការសហការនិងការជួយជ្រោមជ្រែងពីមន្ត្រីនៅមូលដ្ឋាន (មេភូមិ មេឃុំ ឬចៅសង្កាត់)។ មន្ត្រីជំនាញដែលត្រូវបានចាត់តាំងឱ្យទទួលបន្ទុកការងារវាល មានភារកិច្ចទទួលខុសត្រូវ លើការងារកំណត់ព្រំដី

ការងារវាស់វែង ការងារបំពេញទំរង់បែបបទនៃការប្រមូលទិន្នន័យដើម្បីធ្វើការវិនិច្ឆ័យ ឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស និងគោលការណ៍ច្បាប់ ។ ចំនួនមន្ត្រីចុះបំពេញការងារវាលអាចមានច្រើន ឬតិច អាស្រ័យលើតម្រូវការជាក់ស្តែងនៃការងារក្នុងតំបន់ប្រតិបត្តិការនីមួយៗ ។

ប្រសិនបើរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ក្រុង ណាមួយ មិនអាចបំពេញភារកិច្ចតាមលក្ខខ័ណ្ឌសំរាប់អនុវត្តនីតិវិធីនៃការចុះបញ្ជីដី ក្នុងក្របខណ្ឌសមត្ថកិច្ចរបស់ខ្លួន ដោយខ្វះមន្ត្រី ឬដោយសម្ថភាពបច្ចេកទេស រដ្ឋបាលសុរិយោដីនោះអាចស្នើសុំឱ្យរដ្ឋបាលសុរិយោដីរាជធានី ខេត្ត ជួយដល់ការអនុវត្តការងារទាំងនោះបាន ។

១-១- តួនាទីរបស់មន្ត្រីជំនាញ ក្នុងការអនុវត្តការងារវាល :

ក- អំពីការកំណត់ព្រំដី :

- មន្ត្រីទទួលបន្ទុកកំណត់ព្រំដី ត្រូវចុះប្រតិបត្តិការតាមពេលវេលា និងទីកន្លែងដែលបានកំណត់ក្នុងសេចក្តីជូនដំណឹងរបស់អភិបាលស្រុក ខណ្ឌ ក្រុង ។
- មន្ត្រីទទួលបន្ទុកកំណត់ព្រំដី មានសិទ្ធិចូលក្នុងបរិវេណដី ដើម្បីកំណត់ព្រំដី និងវាស់វែង ហើយអាចអញ្ជើញជនពាក់ព័ន្ធឱ្យផ្តល់ពត៌មានដោយផ្ទាល់មាត់ ឯកសារឬ/និង បង្ហាញភស្តុតាងផ្សេងៗ ទាក់ទងនឹងព្រំដីនោះ ។
- មន្ត្រីទទួលបន្ទុកកំណត់ព្រំដី ត្រូវគោរពតាមគោលការណ៍ ដូចខាងក្រោម :
  ក-ក្នុងករណីអ្នកដាក់ពាក្យ និងម្ចាស់ដីជាប់ព្រំ មានវត្តមានហើយព្រមព្រៀងគ្នាអំពីព្រំប្រទល់ និងគ្មានភស្តុតាងផ្ទុយ ការកំណត់ព្រំដីត្រូវធ្វើដោយផ្អែកតាមការព្រមព្រៀង ។
  ខ-ក្នុងករណី ម្ចាស់ដីជាប់ព្រំមិនមានវត្តមាន ការកំណត់ព្រំដីត្រូវធ្វើ ដោយផ្អែកតាមឯកសារដែលមាន និងភស្តុតាង ជាលក្ខណៈរូប ជាលាយលក្ខណ៍អក្សរ ឬផ្តល់ពត៌មានដោយផ្ទាល់មាត់ ទាក់ទងនិងព្រំដីនោះ ។
  គ-ក្នុងករណីក្បាលដីដែលស្នើសុំចុះបញ្ជីស្ថិតនៅជាប់នឹងដីសាធារណៈ ឬជាប់នឹងក្បាលដីដែលប្រើប្រាស់ជាសាធារណៈ ការកំណត់ព្រំដីត្រូវធ្វើដោយយោងតាមចំណុច(ក) ឬ (ខ) ខាងលើ ។

ឃ-វិវាទអំពីព្រំដី ដែលមិនអាចដោះស្រាយបានក្នុងពេលកំណត់ព្រំដី ត្រូវបញ្ជូនទៅធ្វើការសំរុះសំរួលនៅថ្នាក់ស្រុក ខណ្ឌ ក្រុង តាមនីតិវិធីដែលបានកំណត់ក្នុងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មការសុរិយោដី ។

ខ- អំពីការវាស់វែង និងការកំណត់ទីតាំងក្បាលដី :

ក្រោយពីបានកំណត់ព្រំដីរួច មន្ត្រីទទួលបន្ទុកវាស់វែងត្រូវធ្វើការវាស់វែងទៅតាមតម្រូវការនៃការកសាងផែនទីក្បាលដី (Parcel Map) គំនូសបង្ហាញទីតាំងក្បាលដី និងផែនទីមានលក្ខណៈដាច់ដោយដុំ (Sporadic Index Map) ក្នុងតំបន់នីមួយៗ ។

ក្នុងប្រព័ន្ធនេះ ការវាស់វែងអាចប្រព្រឹត្តទៅបានតាមវិធីពីរ អាស្រ័យទៅលើលក្ខណៈនៃភូមិសាស្ត្រ និងឧបករណ៍វាស់វែង :

\+ លទ្ធផលនៃការវាស់វែង ដែលធ្វើឡើងដោយប្រើឧបករណ៍ខ្សែម៉ែត្រ ឬ ខ្សែម៉ែត្រនិងព្រីស (Prism) ក្នុងទីតាំងដែលមិនទាន់មានរូបថតពីអាកាស ឬមានរូបថតពីអាកាសតែមិនទាន់អាចភ្ជាប់ចំណុចប្រទពីវិភាគបាន អាចកសាងបានគំនូសបង្ហាញផែនទីក្បាលដី និង ទីតាំងក្បាលដី ។

ក្នុងការវាស់វែង ដើម្បីកសាងគំនូសបង្ហាញទីតាំងក្បាលដី មន្ត្រីជំនាញត្រូវធ្វើការវាស់វែងដោយចងភ្ជាប់រាល់ចំណុចកាច់ ជ្រុងដីទៅនឹងចំណុចគោល (Point de repere) រឹងមាំស្ថិតស្ថេរ (ប្រសិនជាមាន) ឱ្យបានពីរចំណុចយ៉ាងតិច ។

\+ លទ្ធផលនៃការវាស់វែងដែលធ្វើឡើង ដោយប្រើឧបករណ៍ទំនើប មាន Theodolite, Total Station , EDM , GPS ឬ Orthophoto អាចកសាងផែនទីក្បាលដីដែលមាននិយាមកាបាន ។

ហើយនៅពេលដែលការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ដំណើរការមកដល់តំបន់នេះ គេអាចបញ្ចូលប្រព័ន្ធចុះបញ្ជីដាច់ដោយដុំជាមួយប្រព័ន្ធចុះបញ្ជីថ្មីបាន ។

គ- អំពីការវិនិច្ឆ័យ :

\- មន្ត្រីទទួលបន្ទុកការងារវិនិច្ឆ័យមានសិទ្ធិសាកសួរយកពត៌មានចាំបាច់សំរាប់អនុវត្តការងារវិនិច្ឆ័យ អាចអញ្ជើញជនពាក់ព័ន្ធឱ្យផ្តល់ពត៌មានដោយផ្ទាល់មាត់ ឯកសារ ឬ/និងវត្ថុតាងផ្សេងៗ ដែលទាក់ទងនឹងការវិនិច្ឆ័យ ។

- មន្ត្រីទទួលបន្ទុកការងារវិនិច្ឆ័យ ត្រូវកត់ត្រាពត៌មានអំពី ម្ចាស់ដីក្បាលដី ព្រមទាំងសិទ្ធិ និងបន្ទុកទាំងអស់ដែលមានលើក្បាលដី ចូលក្នុងទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី រួចឱ្យអ្នកជាប់ពាក់ព័ន្ធទាំងអស់ផ្តិតមេដៃ ហើយមន្ត្រីវិនិច្ឆ័យនោះក៏ត្រូវចុះហត្ថលេខានិងឈ្មោះ ទទួលខុសត្រូវលើឯកសារនោះផងដែរ ។
  បន្ទាប់មក ទំរង់បែបបទនេះ ក៏ត្រូវដាក់ជូនរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ក្រុង ពិនិត្យ និងចុះហត្ថលេខា បញ្ជាក់ ។
- ក្នុងករណីមានវិវាទកើតឡើង ទាក់ទងនឹងព្រំប្រទល់ក្បាលដីក្តី ទាក់ទងនឹងសិទ្ធិលើក្បាលដីក្តី មន្ត្រីទទួលបន្ទុកការងារវិនិច្ឆ័យ ត្រូវកត់ត្រាចូលក្នុងទំរង់បែបបទនៃការប្រមូលទិន្នន័យនោះថា <u>ជាដីមានទំនាស់</u> និងបញ្ជាក់អំពីប្រភេទនៃទំនាស់នោះផង ។

១-២- អំពីសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកកាន់កាប់ដី ឬអ្នកតំណាងស្របច្បាប់ :

អ្នកកាន់កាប់ដី ឬអ្នកតំណាងស្របច្បាប់របស់ជននេះ មានកាតព្វកិច្ចចូលរួម និងសហការក្នុងការងារកំណត់ព្រំដី វាស់វែង និងវិនិច្ឆ័យ ដោយផ្តល់ពត៌មានពិត ដោយផ្ទាល់មាត់ ជាលាយលក្ខណ៍អក្សរ ឬភស្តុតាងផ្សេងៗ ទាក់ទងនឹងក្បាលដីរបស់ខ្លួន ឬក្បាលដីដែលខ្លួនត្រូវបានចាត់ធ្វើជាតំណាង ឬក្បាលដីអ្នកជាប់ព្រំ ជូនមន្ត្រីជំនាញ ។

ជនណាដែលបានផ្តល់ពត៌មានខុស ដោយចេតនា ឬបំភាន់មន្ត្រីសុរិយោដីក្នុងពេលបំពេញបេសកម្ម ឬបំភាន់ ក្នុងការ ចុះបញ្ជីដី ត្រូវទទួលទោសតាមមាត្រា២៥២ នៃច្បាប់ភូមិបាល ។

ក្នុងរយៈពេលប្រតិបត្តិការរបស់មន្ត្រីជំនាញ អ្នកកាន់កាប់ដី ឬអ្នកតំណាងស្របច្បាប់របស់ជននេះ ឬជនមានប្រយោជន៍ពាក់ពន្ធ័ មានសិទ្ធិជំទាស់ ឬតវ៉ាប្រសិនបើខ្លួនយល់ថា ទិន្នន័យដែលមន្ត្រីជំនាញបានកត់ត្រាចូលក្នុងទំរង់បែបបទនៃការប្រមូលទិន្នន័យ ឬឯកសារផ្សេងទៀតទាក់ទងនឹងការវិនិច្ឆ័យនោះ មិនត្រឹមត្រូវ ឬខុសពីចម្លើយរបស់ខ្លួន ។

១-៣- អំពីសិទ្ធិភារកិច្ចរបស់អាជ្ញាធរដែនដី :

ក- អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវបង្កលក្ខណៈងាយស្រួល សហការឱ្យបានល្អ និងផ្តល់សុវត្ថិភាព ដល់កិច្ចប្រតិបត្តិការរបស់មន្ត្រីជំនាញ ដើម្បីធ្វើឱ្យសំរេចនូវការអនុវត្តនីតិវិធីនៃការវិនិច្ឆ័យ ដែលប្រព្រឹត្តទៅ នៅក្នុងដែនដីរបស់ខ្លួនទទួលខុសត្រូវ ។

ក្នុងករណីចាំបាច់ រដ្ឋបាលសុរិយោដីអាចស្នើសុំទៅអាជ្ញាធរដែនដី ឬកំលាំងប្រដាប់អាវុធ ឱ្យជួយជ្រោមជ្រែង ដល់ការអនុវត្តការងារវាល ។

ខ- ក្នុងការផ្តល់យោបល់លើពាក្យស្នើសុំ ឬឯកសារពត៌មានពាក់ពន្ធ័នឹងការកំណត់សិទ្ធិលើដី ពិសេសការផ្តល់យោបល់ទាក់ទងនឹងលក្ខខ័ណ្ឌនៃការកាន់កាប់ដី ប្រភព និង កាលបរិច្ឆេទនៃការកាន់កាប់ដី ត្រូវតែជាពត៌មានពិត មិនបំភ្លៃ បំភាន់ ឬផ្អែកលើមនោសញ្ចេតនាបុគ្គល ដែលជាហេតុនាំឱ្យការកំណត់សិទ្ធិ លើអចលនវត្ថុមិនបានត្រឹមត្រូវ និងនាំឱ្យកើតមានទំនាស់ ។

គ- ក្នុងរយៈពេលនៃការបិទផ្សាយនូវឯកសារវិនិច្ឆ័យ ក្នុងឃុំ ឬសង្កាត់ណា មេឃុំ ឬចៅសង្កាត់នោះ ត្រូវមានវត្តមាន តាមតម្រូវការជាក់ស្តែងនៃការងារ ។ ក្នុងករណីមានធុរៈ មេឃុំ ឬចៅសង្កាត់នោះ ត្រូវចាត់តំណាងរបស់ខ្លួន មកជំនួស ។

២. ការងារនៅការិយាល័យ :

ទិន្នន័យដែលប្រមូលបានពីការងារវាល មានគុណភាពពីរ :

- អាចបញ្ចូលក្នុងកំព្យូទ័រ ដើម្បីកសាងផែនទីក្បាលដី ផែនទីបង្ហាញទីតាំងដីស្នើសុំ ផែនទីមានលក្ខណៈដាច់ដោយដុំ កសាងបញ្ជីឈ្មោះម្ចាស់ដី និងសៀវភៅចុះបញ្ជីអចលនវត្ថុចំពោះក្បាលដីទាំងឡាយដែលការវាស់វែង ត្រូវបានធ្វើឡើងដោយឧបករណ៍ទំនើប (រាល់ចំណុចជ្រុងនៃក្បាលដីនីមួយៗ ត្រូវបានកំណត់ដោយនិយាមកា) ។
- អាចគូរផែនទីក្បាលដី គូរគំនូរបង្ហាញទីតាំងដីស្នើសុំ ផែនទីមានលក្ខណៈដាច់ដោយដុំ កសាងបញ្ជីឈ្មោះម្ចាស់ដី និង សៀវភៅចុះបញ្ជីអចលនវត្ថុចំពោះក្បាលដីដែលការវាស់វែង ត្រូវបានធ្វើឡើងដោយឧបករណ៍សាមញ្ញ (មិនអាចបង្កើតនិយាមកា តាមចំណុចជ្រុងនៃក្បាលដីនីមួយៗបាន) ។

របៀបរៀបចំខ្លឹមសារ និងការកាន់កាប់ ឯកសារសុរិយោដី : សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីអចលនវត្ថុ ទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី បញ្ជីឈ្មោះ

ម្ចាស់ដី ផែនទីក្បាលដី ផែនទីមានលក្ខណៈដាច់ដោយដុំ និងឯកសារ រណបផ្សេងៗទៀត ត្រូវកំណត់ ដោយប្រកាសរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ដំណាក់កាលទី ៣ : **អំពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ**

ឯកសារនៃការវិនិច្ឆ័យដែលត្រូវបិទផ្សាយរួមមាន ផែនទីក្បាលដី គំនូសបង្ហាញទីតាំងក្បាលដី និងបញ្ជីឈ្មោះម្ចាស់ដី ។

ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ត្រូវធ្វើឡើងក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ នៅសាលាស្រុក ខណ្ឌ ក្រុងដែលក្បាលដីនោះស្ថិតនៅ ។ សេចក្តីចម្លងនៃឯកសារទាំងនេះ ក៏ត្រូវបិទផ្សាយផងដែរ នៅសាលាឃុំ សង្កាត់ ដែលក្បាលដីស្នើសុំចុះបញ្ជីនោះស្ថិតនៅ ។

អភិបាលស្រុក ខណ្ឌ ក្រុង ត្រូវជូនដំណឹងអំពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យនេះ ដល់អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីដី ។ សេចក្តីជូនដំណឹងនេះត្រូវធ្វើឡើងយ៉ាងតិច៧(ប្រាំពីរ)ថ្ងៃ មុនថ្ងៃបើកការផ្សព្វផ្សាយជាសាធារណៈ ហើយត្រូវបិទផ្សាយនៅកន្លែងដែលងាយមើលឃើញ នៅក្នុងភូមិ នៅសាលាឃុំ សង្កាត់ និងនៅសាលាស្រុក ខណ្ឌ ក្រុង។

ក្នុងរយៈពេលនៃការបិទផ្សាយ សាមីអ្នកកាន់កាប់ដី ឬអ្នកតំណាងស្របច្បាប់របស់ខ្លួន និងជនដែលមានផលប្រយោជន៍ពាក់ពន្ធ័នឹងក្បាលដីស្នើសុំចុះបញ្ជី អាចជូនដំណឹងពីការជំទាស់របស់ខ្លួន ឬធ្វើបណ្តឹងជំទាស់ ឬបណ្តឹងតវ៉ា ជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ ដល់អ្នកប្រចាំការកន្លែងបិទផ្សាយនៅសាលាស្រុក ខណ្ឌ ក្រុង អំពីភាពខ្វះចន្លោះ ឬ ភាពខុសឆ្គង នៃឯកសារដែលបានបិទផ្សាយ ។ រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ក្រុង ត្រូវស៊ើបអង្កេតលើការជំទាស់នោះ ដោយផ្អែកតាមឯកសារ និងពត៌មានទាំងអស់ដែលប្រមូលបានក្នុងពេលអនុវត្តនីតិវិធី ។

ក្នុងករណីដែលការស៊ើបអង្កេតនោះបង្ហាញថា ការជំទាស់ ឬការតវ៉ា មានលក្ខណៈសមហេតុផល រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ក្រុង អាចធ្វើការកែតម្រូវការខុសឆ្គង ឬការភ្លេច

ភ្ញាំងដែលមិនប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់នៃជនណាមួយ ។ ការកែតម្រូវផ្សេងទៀតក្នុងឯកសារនៃការវិនិច្ឆ័យ អាចធ្វើបានដរាបណាមានការយល់ព្រមពីជនពាក់ព័ន្ធដែលទទួលឥទ្ធិពលពីការកែតម្រូវនោះ ។

ក្នុងករណីដែលការស៊ើបអង្កេតនោះបង្ហាញថា ការជំទាស់ ឬការតវ៉ាមានលក្ខណៈមិនសមហេតុផល ឬមិនអាចសម្រុះសម្រួលបាន ការជំទាស់ ឬការតវ៉ាទាំងនោះត្រូវដាក់ឱ្យធ្វើការសម្រុះសម្រួល និងដោះស្រាយ តាមនីតិវិធីដែលបានកំណត់ក្នុងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ។

បណ្តឹងនីមួយៗត្រូវធ្វើកំណត់ត្រាដោយឡែក ហើយត្រូវបញ្ជាក់អំពី កម្មវត្ថុនៃបណ្តឹង ឈ្មោះ និងស្នាមមេដៃម្ចាស់បណ្តឹង ឈ្មោះ និងហត្ថលេខាមន្ត្រីកត់ត្រា និងមានការបញ្ជាក់ដឹងឮ ពីមេឃុំ ចៅសង្កាត់ ឬតំណាង ។

ក្នុងករណីមិនមានការជំទាស់ ឬតវ៉ា ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈ ទិន្នន័យដែលបានកត់ត្រាក្នុងឯកសារបិទផ្សាយនោះ ត្រូវបានចាត់ទុកជាទិន្នន័យសុក្រឹតដែលអាចកំណត់យកជាផ្លូវការតាមច្បាប់បាន ។

ដំណាក់កាលទី ៤ : **អំពីការសំរេចលើឯកសារ :**

១- ក្រោយពីផុតរយៈពេលនៃការបិទផ្សាយជាសាធារណៈ នូវឯកសារនៃការវិនិច្ឆ័យ មន្ត្រីជំនាញទទួលបន្ទុកការងារវិនិច្ឆ័យ ត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការវិនិច្ឆ័យតាម ខ្លឹមសារខាងក្រោម :

ក- លទ្ធផលសំរេចបាន :

- ចំនួនក្បាលដីសរុបដែលបានធ្វើការវិនិច្ឆ័យ
- ចំនួនក្បាលដីដែលមានលក្ខណៈត្រឹមត្រូវនិងគ្មានវិវាទ ហើយគួរផ្តល់ប័ណ្ណ
- ចំនួនក្បាលដីដែលមិនគួរផ្តល់ប័ណ្ណជូន មានជាអាទិ៍ :
  + ក្បាលដីស្នើសុំត្រូវបានកាន់កាប់ក្រោយច្បាប់ភូមិបាលចូលជាធរមាន
  + ក្បាលដីកំពុងមានវិវាទ

- បញ្ជូនទៅគណៈកម្មការសុរិយោដី
- កំពុងមានបណ្តឹង និងកំពុងដំណើរការនីតិវិធី នៅតុលាការ ។

ខ- មន្ត្រីជំនាញដែលទទួលបន្ទុកការងារវិនិច្ឆ័យត្រូវធ្វើការវាយតម្លៃ លើកសំណើផ្តល់សិទ្ធិលើដី ឬអចលនវត្ថុ ជូនអ្នកកាន់កាប់ដីដែលបានស្នើសុំ ឬ អាជ្ញាធរដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងតាមប្រភេទ : កម្មសិទ្ធិ ភោគៈ សម្បទាន មិនត្រូវផ្តល់ប័ណ្ណជាលក្ខណៈឯកជន ឬរក្សាទុកជាទ្រព្យរដ្ឋ ដោយយោងតាមច្បាប់បទដ្ឋានគតិយុត្តពាក់ព័ន្ធ និងឯកសារភស្តុតាង ដែលប្រមូលបាន ។

គ- មន្ត្រីជំនាញដែលទទួលបន្ទុកការងារវិនិច្ឆ័យ ត្រូវគូសក្បាលដីដែលមានលក្ខណៈត្រឹមត្រូវ និងគ្មានទំនាស់ ចូលក្នុង ផែនទីមានលក្ខណៈដាច់ដោយដុំ ។

២- ក្រោយពីផែនទីក្បាលដី និងបញ្ជីឈ្មោះអ្នកកាន់កាប់ដី ត្រូវបានកែតម្រូវរួចហើយ មន្ត្រីជំនាញ ដែលទទួលបន្ទុកការងារវិនិច្ឆ័យក្បាលដីតាមពាក្យស្នើសុំ ត្រូវរៀបចំសំណុំឯកសារដូចខាងក្រោម ដើម្បីដាក់ជូនរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ក្រុង ពិនិត្យ និង ចុះហត្ថលេខាបញ្ជូនសំណុំរឿងទាំងមូលទៅលោកអភិបាលស្រុក ខណ្ឌ ក្រុង ពិនិត្យ និង បញ្ជូនបន្តទៅរដ្ឋបាលសុរិយោដីរាជធានី ខេត្ត ។

- ពាក្យស្នើសុំចុះបញ្ជីដី
- ឯកសារនៃការវិនិច្ឆ័យ (ឯកសារទាក់ទងនឹងការកំណត់ព្រំដី ការវាស់វែងដី ទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ផែនទីក្បាលដី)
- សេចក្តីជូនដំណឹងស្តីពីកាលបរិច្ឆេទនៃការកំណត់ព្រំដី
- ការដកស្រង់ផែនទីមានលក្ខណៈដាច់ដោយដុំ ឬគំនូសបង្ហាញទីតាំងក្បាលដី
- សេចក្តីជូនដំណឹងពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ
- កំណត់ហេតុ បិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ
- របាយការណ៍ស្តីពីលទ្ធផលនៃការវិនិច្ឆ័យ
- ពាក្យបណ្តឹងជំទាស់ តវ៉ាដែលពុំអាចដោះស្រាយបាន ប្រសិនបើមាន
- លិខិតស្នើសុំកែតម្រូវ ប្រសិនបើមាន
- កំណត់ហេតុសំរុះសំរួលវិវាទដែលបានដោះស្រាយរួច ប្រសិនបើមាន ។

ជំណាក់កាលទី៥ : **អំពីការចេញប័ណ្ណដី** :

បន្ទាប់ពីបានទទួលសំណុំរឿងពីរដ្ឋបាលសុរិយោដី ស្រុក ខណ្ឌ ក្រុង រដ្ឋបាលសុរិយោដី រាជធានី ខេត្ត ត្រូវ :

- ពិនិត្យនិងផ្តល់យោបល់ជូនអភិបាលរាជធានី ខេត្ត សំរេចយល់ព្រមឱ្យចេញប័ណ្ណ ឬជំទាស់ត្រង់ចំណុចណា ឬច្រានចោលទាំងស្រុងតែម្តង ។

  ករណីអភិបាលរាជធានី ខេត្តសំរេចយល់ព្រមឱ្យចេញប័ណ្ណ រដ្ឋបាលសុរិយោដីរាជធានី ខេត្ត ដែលបានទទួលប្រតិភូកម្មហត្ថលេខាពីក្រសួងអាណាព្យាបាលអាចចេញប័ណ្ណជូនសាមីអ្នកស្នើសុំតែម្តង ។

  ករណីអភិបាលរាជធានី ខេត្ត ជំទាស់ត្រង់ចំណុចណាមួយ ឬច្រានចោល អភិបាលរាជធានី ខេត្តនោះត្រូវបញ្ជាក់ឱ្យបានច្បាស់ពីមូលហេតុនៃការជំទាស់ ឬការច្រានចោលនោះ ដើម្បីរដ្ឋបាលសុរិយោដីជំរាបទៅអ្នកស្នើសុំឱ្យបានជ្រាប ។

- ពិនិត្យ និងផ្តល់យោបល់ជូនអភិបាលរាជធានី ខេត្ត សំរេចយល់ព្រម ឬជំទាស់ចំណុចណាមួយ ឬច្រានចោលមិនផ្តល់ប័ណ្ណជូនអ្នកស្នើសុំ ។

  ករណីអភិបាលរាជធានី ខេត្តសំរេចយល់ព្រម រដ្ឋបាលសុរិយោដីរាជធានី ខេត្តដែលមិនទាន់បានទទួលប្រតិភូកម្មហត្ថលេខាពីក្រសួងអាណាព្យាបាល ត្រូវបញ្ជូនសំណុំរឿងនេះបន្តមកអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ដើម្បីពិនិត្យ បន្ថែមតាមគោលការណ៍ជំនាញ បើឃើញថាត្រឹមត្រូវ ត្រូវធ្វើការចុះបញ្ជី ហើយចេញ ប័ណ្ណជូនអ្នកស្នើសុំ ។

  តែបើមានចំណុចណាមិនទាន់ត្រឹមត្រូវ ឬមិនគ្រប់គ្រាន់ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ត្រូវណែនាំរដ្ឋបាលសុរិយោដីរាជធានី ខេត្ត កែតម្រូវ ឬបំពេញឡើងវិញដោយផ្អែកលើគោលការណ៍ជំនាញ និងច្បាប់ ជាមូលដ្ឋាន ។

  ករណីអភិបាលរាជធានី ខេត្ត ជំទាស់ចំណុចណាមួយ ឬច្រានចោលទាំងស្រុងតែម្តង រដ្ឋបាលសុរិយោដី រាជធានី ខេត្ត ត្រូវពិនិត្យមើលចំណុចនោះឡើងវិញ ហើយរាយការណ៍សុំ

យោបល់អភិបាលរាជធានី ខេត្តនោះជាលើកទី២ ប្រសិនពិនិត្យឃើញថា មូលហេតុនៃការជំទាស់ ឬច្រានចោលនោះ មិនសមស្របនឹងសភាពការណ៍ពិតដូចដែលគាត់បានដឹង ។ ករណីដែល អភិបាលរាជធានី ខេត្តនៅតែរក្សាការសម្រេចលើកទីមួយ រដ្ឋបាលសុរិយោដីរាជធានី ខេត្ត ត្រូវបញ្ជូន សំណុំរឿងនោះ មកអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ដោយភ្ជាប់យោបល់ជំទាស់ ឬច្រានចោល និងរបាយការណ៍ពិនិត្យឡើងវិញ មកជាមួយ ដើម្បីអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ពិនិត្យ និងសំរេច ។

គោលការណ៍នៃការចេញប័ណ្ណដី :

១) សមត្ថកិច្ចក្នុងការសំរេចលើទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី និងការចេញប័ណ្ណដី ត្រូវបានប្រគល់សិទ្ធិជូនរដ្ឋបាលសុរិយោដីរាជធានី ខេត្ត ។
ឯសមត្ថកិច្ចក្នុងការវាស់វែងគឺ អាស្រ័យទៅលើសមត្ថភាពបច្ចេកទេសរបស់មន្ត្រីមូលដ្ឋាន និងឧបករណ៍ប្រើប្រាស់ដែលមាន ។ ករណីមិនអាចធ្វើបាន រដ្ឋបាលសុរិយោដីរាជធានី ខេត្ត ត្រូវលើកសំណើមករដ្ឋបាលសុរិយោដីថ្នាក់កណ្តាល ដើម្បីឧបត្ថម្ភ ។

២) ចេញវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ (ប័ណ្ណកម្មសិទ្ធិ) ជូនចំពោះក្បាលដីណាដែលម្ចាស់សិទ្ធិបានចូលកាន់កាប់ដីមុន ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ឬបានកាន់កាប់បន្តពីភោគីដើម មានលក្ខណៈត្រឹមត្រូវតាមច្បាប់ មិនមានការជំទាស់ មានរយៈពេល៥ឆ្នាំ យ៉ាងតិច គិតពីថ្ងៃចូលកាន់កាប់ដីមកដល់ថ្ងៃចេញប័ណ្ណ ហើយក្បាលដីនោះត្រូវបានកសាងផែនទីក្បាលដី ដែលមាននិយាមកាច្បាស់លាស់រួច ។

៣) ចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ(ប័ណ្ណភោគៈ)ជូន ចំពោះក្បាលដីណាដែលម្ចាស់សិទ្ធិបានចូលកាន់កាប់ដីមុន ថ្ងៃទី៣០ ខែ សីហា ឆ្នាំ២០០១ ឬកាន់កាប់បន្តពីភោគីដើម មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ហើយមានរយៈតិចជាង ៥ឆ្នាំ ឬក្នុង

ករណីដែលបានកាន់កាប់លើសពី ៥ឆ្នាំ តែមិនទាន់បានកសាងផែនទីក្បាលដីដែលមាននិយាមកា ។
ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុដែលបានផ្តល់ឱ្យតាមនីតិវិធីចុះបញ្ជីថ្មីនេះអាចដូរយកវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុបាន នៅពេលដែលរយៈពេលនៃការកាន់កាប់ដីនោះ បានគ្រប់៥ឆ្នាំ ឬលើស ហើយប្លង់សុរិយោដីត្រូវបានកសាងរួច ។

៤) អាចចេញប័ណ្ណជូនបាន ចំពោះតែក្បាលដីណាដែលគ្មានទាក់ទិននឹងវិវាទ ឬមានវិវាទតែត្រូវបានដោះស្រាយចប់ជាស្ថាពរ ។

៥) មិនអាចចេញប័ណ្ណជូនបានទេ ចំពោះក្បាលដីដែលអ្នកស្នើសុំបានចូលកាន់កាប់ដីក្រោយច្បាប់ភូមិបាលចូលជាធរមាន ។

៦) មិនអាចចេញប័ណ្ណជូនជាឯកជនបានទេ ចំពោះក្បាលដីណាដែលត្រូវបានកំណត់ទាំងស្រុងជាទ្រព្យសម្បត្តិសាធារណៈ ឬទុកបំរើសេវាសាធារណៈ ។
ចំពោះក្បាលដីស្នើសុំចុះបញ្ជី ដែលមានចំណែកណាមួយត្រួតគ្នាលើដីដែលជាសម្បត្តិសាធារណៈ ឬទុកបំរើសេវាសាធារណៈ អាចចេញប័ណ្ណជូនបុគ្គលឯកជនបាន លុះត្រាតែចំណែកត្រួតគ្នានោះត្រូវបានដកចេញពីទំហំសរុបនៃក្បាលដី ។

៧) នៅពេលទទួលប័ណ្ណថ្មី ម្ចាស់ដីត្រូវប្រគល់ឯកសារទាំងអស់ទាក់ទងនឹងសិទ្ធិលើក្បាលដីនោះដែលខ្លួនមានពីមុនមក ជូនមន្ត្រីសុរិយោដី ។
រាល់ឯកសារទាក់ទងនឹងសិទ្ធិលើក្បាលដីដែលសាមីម្ចាស់ដីមិនបានប្រគល់ ឬមិនបានរាយការណ៍ពីការប្រើប្រាស់ ជូនមន្ត្រីជំនាញមានសមត្ថកិច្ច ត្រូវបានចាត់ទុកជាមោឃៈ និង មិនមានអានុភាពតាមផ្លូវច្បាប់ ។

៨) ការប្រគល់ប័ណ្ណដី ត្រូវបានធ្វើឡើងដោយមានសៀវភៅសំរាប់កត់ឈ្មោះ និងចុះហត្ថលេខាមន្ត្រីប្រគល់ និងកត់ ឈ្មោះ រូបផ្តិតមេដៃអ្នកទទួល ទុកជាភស្តុតាងផង ។

ការប្រគល់ប័ណ្ណដី ត្រូវប្រព្រឹត្តទៅនៅអង្គភាពសុរិយោដីដែលមានសមត្ថកិច្ច ។ មន្ត្រីសុរិយោដី មិនត្រូវបានអនុញ្ញាតឱ្យប្រគល់ប័ណ្ណដី ជូនបុគ្គលក្រៅពីម្ចាស់សិទ្ធិពិតប្រាកដឡើយ លើកលែង :

- ករណីម្ចាស់សិទ្ធិទទួលមរណៈភាព ឬអវត្តមាន ឬត្រូវបាត់ខ្លួន ឬបាត់បង់សមត្ថភាព ហើយត្រូវបានច្បាប់ទទួល ស្គាល់អ្នកតំណាងស្របច្បាប់
- ករណីពិសេស និងចាំបាច់ ម្ចាស់សិទ្ធិអាចប្រគល់សិទ្ធិឱ្យអ្នកតំណាងស្របច្បាប់របស់ខ្លួនមកទទួលយកប័ណ្ណជំនួស តែត្រូវបញ្ជាក់ច្បាស់ជាលាយលក្ខណ៍អក្សរអំពីហេតុដែលមិនអាចមកទទួលយកនៅរដ្ឋបាលសុរិយោដី ។

៩) ចំពោះនីតិបុគ្គល ប័ណ្ណត្រូវចុះឈ្មោះអង្គភាព ឬនាមករណ៍ (នីតិបុគ្គលសាធារណៈ មានជាអាទិ៍ សាលារៀន សាលាឃុំ ...,នីតិបុគ្គលឯកជន មានជាអាទិ៍ សមាគម ក្រុមហ៊ុន ....) គឺមិនត្រូវចុះឈ្មោះរូបវន្តបុគ្គលជាដាច់ខាត ។

ចំពោះដី ឬអចលនវត្ថុរបស់សម្ហហភាព ដូចជា វត្ត ឬសហគមន៍ជនជាតិដើមភាគតិច.. នៅក្នុងប័ណ្ណក៏ត្រូវចុះឈ្មោះ វត្ត ឬសហគមន៍ ...ដែរ គឺមិនត្រូវចុះឈ្មោះរូបវន្តបុគ្គលជាតំណាងឡើយ ។

ទាក់ទងដល់ការប្រើសិទ្ធិ និងការបំពេញកាតព្វកិច្ចផ្សេងៗ ក្នុងការអនុវត្តនីតិវិធីនៃការវិនិច្ឆ័យ នីតិបុគ្គលនានាក៏ដូច ជាសម្ហហភាពទាំងអស់នោះ ត្រូវជ្រើសរើសតំណាងស្របច្បាប់រៀងខ្លួន តាមវិធីផ្សេងគ្នា ដូចជា នីតិបុគ្គលសាធារណៈ មាន លិខិតតែងតាំង នីតិបុគ្គលឯកជន មានការជ្រើសតាំងបណ្ណាធិការក្រុមហ៊ុន ឬប្រធានសមាគម បើវត្តមានប្រធានគណៈកម្មការវត្ត បើសហគមន៍ជនជាតិដើមភាគតិច មានមេសហគមន៍... ។ល។ តំណាងស្របច្បាប់ទាំងនេះ មានសិទ្ធិនិងកាតព្វកិច្ចទាក់ទង នឹងដី ឬអចលនវត្ថុ ដូចម្ចាស់សិទ្ធិជារូបវន្តបុគ្គលដែរ ។

ឯប័ណ្ណដី ឬអចលនវត្ថុ របស់នីតិបុគ្គលសាធារណៈ និងឯកជន ត្រូវប្រគល់ឱ្យតំណាងស្របច្បាប់នៃនីតិបុគ្គលនីមួយៗ ជាអ្នកទទួលយក និងរក្សាទុក ។

ចំពោះប័ណ្ណដី ឬអចលនវត្ថុរបស់សមូហភាព ត្រូវប្រគល់ជូនតំណាងស្របច្បាប់ ឬមេសហគមន៍ ទទួលយក និងរក្សាទុក។

ភ្នំពេញ ,ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៩

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

អ៊ឹម ឈុនលឹម

កន្លែងទទួល :

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី

  "ដើម្បីជូនជ្រាប"
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់រាជធានី-ខេត្ត

  "ដើម្បីសហការអនុវត្ត"
- គ្រប់អគ្គនាយកដ្ឋានក្រោមឱវាទក្រសួង
- គ្រប់មន្ទីរ ដ.ន.ស.ស រាជធានី-ខេត្ត

  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ៣៧០៣ ប្រ.ក

ប្រកាស
ស្តីពី
ការបង្កើត មណ្ឌលអប់រំកែប្រែទី៤ ហៅកាត់ "ម៤"

****

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៣ ស្តីពីការបង្កើតអគ្គនាយកដ្ឋានពន្ធនាគារ

-បានឃើញសេចក្តីជូនដំណឹងលេខ ៨៣៤ សជណ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីការយល់ព្រមផ្ទេរផ្ទៃដីចំនួន ៨៤៦ ហិចតា ចេញពីដែនព្រៃការពារទុកអចិន្ត្រៃយ៍ និងគោលការណ៍បង្កើតមណ្ឌលអប់រំកែប្រែទី៤ មានលក្ខណៈជាពន្ធនាគារកសិកម្ម

-តាមសំណើរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ

ស ម្រេ ច

ប្រការ ១ : ត្រូវបានបង្កើតមណ្ឌលអប់រំកែប្រែទី៤ ហៅកាត់ ម៤ ចំណុះអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ ។

ប្រការ ២ : មណ្ឌលអប់រំកែប្រែទី៤ មានលក្ខណៈជាពន្ធនាគារកសិកម្ម មានចំណុះផ្ទុកអ្នកទោសចំនួន ២.៥០០នាក់ មានផ្ទៃដីចំនួន ៨៤៦ ហិចតា និងមានទីតាំងនៅក្នុងភូមិសាស្រ្តឃុំផ្ទះរុង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ។

ប្រការ ៣ : **អំពីតួនាទី ភារកិច្ច រចនាសម្ព័ន្ធ របស់មណ្ឌលអប់រំកែប្រែទី៤**

មណ្ឌលអប់រំកែប្រែទី៤ មានសាខាចំណុះចំនួន ០៥ និងមានតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធដូចមានចែងក្នុងប្រកាសលេខ ៤០៤ ប្រក ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៧ របស់ក្រសួងមហាផ្ទៃ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំង របស់នាយកដ្ឋាន លេខាធិការដ្ឋាន មណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី-ខេត្ត ចំណុះអគ្គនាយកដ្ឋានពន្ធនាគារ ។

ប្រការ ៤ : មណ្ឌលអប់រំកែប្រែទី៤ ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើនឹងអនុប្រធាននាយកដ្ឋាន និងមានអនុប្រធានមួយចំនួនមានឋានៈស្មើនឹងប្រធានការិយាល័យថ្នាក់កណ្តាល ជាជំនួយការ ។

ប្រការ ៥ : សាខានីមួយៗចំណុះមណ្ឌលអប់រំកែប្រែទី៤ ដឹកនាំដោយប្រធានមួយរូបដែលជាអនុប្រធានមណ្ឌល និងមានអនុប្រធានមួយចំនួនមានឋានៈស្មើនឹងអនុប្រធានការិយាល័យថ្នាក់កណ្តាល ជាជំនួយការ ។

ប្រការ ៦ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៧ : អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ អគ្គាធិការ នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាលនិងនគរបាល អភិបាលរាជធានី-ខេត្ត ប្រធាននាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងគ្រប់អង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ ៧ ឆ្នាំ២០០៩

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង

កន្លែងទទួល :
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងយុត្តិធម៌
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

  (*ដើម្បីជូនជ្រាប*)
- ដូចប្រការ ៧

  (*ដើម្បីអនុវត្ត*)
- ឯកសារ កាលប្បវត្តិ